# ការបង្កើតសាលារៀនជំនាន់ថ្មីនៅក្នុងប្រទេសកម្ពុជា

## ឯកសារពិគ្រោះយោបល់: ការពិសោធន៍រចនាសម្ព័ន្ធអភិបាលកិច្ចថ្មីក្នុងការបង្កើតគំរូអប់រំមានគុណភាពខ្ពស់

អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា

សេចក្តីព្រាងចុងក្រោយ

ខែតុលា ឆ្នាំ២០១៨

Kampuchean Action for Primary Education, PO Box 1621, Phnom Penh, Tel: 042-941-481, Fax: 042-941-918, email: kape@kapekh.org, website: www.kapekh.org

# 1. សេចក្តីផ្តើម

## 1.1. គោលបំណងនៃឯកសារ

ឯកសារនេះបានចងក្រងឡើងធ្វើជាឯកសារពិគ្រោះសម្រាប់ជាជំនួយដល់ក្រសួងអប់រំយុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍ឲ្យពិនិត្យឡើងវិញនូវបទពិសោធន៍ដែលមានស្រាប់ នៅក្នុងប្រទេសអំពីការប្រើប្រាស់គោលការណ៍ភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) ក្នុងការលើកកម្ពស់ការងារអភិបាលកិច្ចសាលារៀន ព្រមទាំងបង្កើតសាលារៀនដែលមានស្តង់ដាគុណភាពអប់រំអតិបរមា(ផ្ទុយពីស្តង់ដាអប្បរមា)។ ការកែលម្អអភិបាលកិច្ចសាលារៀនត្រូវបានគេមើលឃើញថាជាមធ្យោបាយគន្លឹះដ៏សំខាន់មួយ សម្រាប់ឈានទៅបង្កើតគំរូអប់រំឲ្យមានគុណភាពខ្ពស់ និងមាននិរន្តរភាព ដែលមានលក្ខណៈស្រដៀងទៅនឹងអ្វីដែលគេសង្កេតឃើញមាននៅក្នុងសាលារៀនឯកជន ប៉ុន្តែកម្ររកឃើញនៅក្នុងសាលារៀនរដ្ឋ។ ឯកសារនេះផ្តោតសំខាន់ទៅលើបទពិសោធន៍របស់អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា (ខេប) ដែលជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ នៅក្នុងកិច្ចខិតខំប្រឹងប្រែបង្កើតគំរូអភិបាលកិច្ចមួយប្រកបដោយជោគជ័យក្រោមកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដែលនេះគឺជាបទពិសោធន៍កម្រិតខ្ពស់ និងឆ្លងផុតពីការអនុវត្តតាមបែបសាមញ្ញៗ ដែលសំដៅទៅលើរបៀបគ្រប់គ្រង និងផ្តល់ហិរញ្ញប្បទាននៅតាមសាលារៀនរដ្ឋ។ ខាងក្រោមនេះជាសេចក្តីពន្យល់លម្អិតបន្ថែម៖

តម្រូវការឲ្យមានសាលារៀនជំនាន់ថ្មីដែលប្រើប្រាស់គំរូអភិបាលកិច្ចថ្មី និងផ្តល់គុណភាពអប់រំខ្ពស់នៅក្នុងសាលារៀនរដ្ឋ កំពុងតែកើនឡើងជាលំដាប់ និងបន្ទាន់ជាមួយនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនូវចំនួនសាលាឯកជនទាំងបឋមសិក្សា និងមធ្យមសិក្សា។

ទោះបីនៅក្នុងអតីតកាលសាលារៀនបែបនោះមានសម្រាប់តែសហគមន៍ជនបរទេស និងមន្ត្រីជាន់ខ្ពស់ក៏ដោយ ប៉ុន្តែឥឡូវនេះវាបានកាន់តែសមស្របសម្រាប់គ្រួសារមានជីវភាពមធ្យមក្នុងប្រទេសកម្ពុជា ដែលកំពុងតែកើនឡើងយ៉ាងច្រើន។ ការវិវត្តទាំងនេះបណ្តាលឲ្យកុមារដែលមកពីគ្រួសារមានជីវភាពមធ្យមជាច្រើនបានចាកចេញពីសាលារដ្ឋ ដើម្បីប្តូរទៅសិក្សានៅតាមសាលាឯកជនវិញ នេះនាំឲ្យកើតឡើងនូវប្រព័ន្ធអប់រំពីរថ្នាក់ដែលអាចនាំដល់ការបែងចែកវណ្ណៈខុសគ្នា និងឈានទៅបង្ករជាផលអាក្រក់ធ្ងន់ធ្ងរដល់សង្គមកម្ពុជា។ ឧទាហរណ៍ ការសិក្សាថ្មីមួយនៃការអភិវឌ្ឍទាំងនេះបានរកឃើញថា អត្រាចុះឈ្មោះចូលរៀនរបស់សិស្សក្នុងខណ្ឌមួយចំនួននៅរាជធានីភ្នំពេញកន្លងមកបានធ្លាក់ចុះចន្លោះពី ៣០%ទៅ៥០% បណ្តាលមកពីសិស្សបានទៅចុះឈ្មោះចូលរៀននៅតាមសាលាឯក[1] ទំនោរស្រដៀងគ្នានេះដែរបច្ចុប្បន្ននេះកំពុងកើតឡើងនៅតាមទីរួមខេត្តមួយចំនួនដូចជាខេត្តកំពង់ចាម ដែលមានអត្រាចុះឈ្មោះចូលរៀននាពេលបច្ចុប្បន្នធ្លាក់ចុះដល់៧៣%[2] ។ ដើម្បីជួយដល់រដ្ឋាភិបាលឲ្យឆ្លើយតបទៅនឹងនិន្នាការទាំងនេះ អង្គការខេបបានបង្កើតគម្រោង

---

[1] KAPE (2013) *Enrollment Trends in Phnom Penh: A Need Assessment,* Phnom Penh: Save the Children

[2] EMIS (2013) *Education Indicators and Statistics,* Phnom Penh: MoEYS

សាលារៀនដៃគូ សម្រាប់ជាការពិសោធន៍ដ៏សំខាន់មួយក្នុងការបង្កើនតួនាទីតួអង្គវិស័យឯកជន (NSAs) នៅក្នុងវិស័យសាធារណៈ(រដ្ឋ) តាមរយៈការប្រើប្រាស់គោលការណ៍ភាពជាដៃគូរវាងរដ្ឋ និងឯកជន។ ខណៈដែលគម្រោងកំពុងបន្តសកម្មភាពការងារនៅឡើយ គម្រោងសាលារៀនដៃគូអាចផ្តល់ជូនរដ្ឋាភិបាលនូវការយល់ដឹងស៊ីជម្រៅ និងមានប្រយោជន៍ ក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីចម្លងគំរូអភិបាលកិច្ចថ្មីនេះទៅអនុវត្តនៅតាមមូលដ្ឋានផ្សេងៗទៀត ជាពិសេសរាជធានីភ្នំពេញ និងបង្កើតយន្តការដើម្បីធានានិរន្តរភាពហិរញ្ញវត្ថុតាមរយៈការបង្កើតមូលនិធិសមធម៌សង្គមមួយដែលបានដាក់ស្នើឡើង។

## 1.2 ការបង្កើតគម្រោងសាលារៀនដៃគូជាមធ្យោបាយលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ និងឯកជននៅក្នុងវិស័យអប់រំសាធារណៈ

គម្រោងសាលារៀនដៃគូ ឬ BSI គាំទ្រដោយអង្គការខេប( KAPE) , មូលនិធិអូកទ្រី(the Oaktree Foundation), ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ(USAID) និងម្ចាស់ជំនួយផ្សេងៗទៀតតាំងពីឆ្នាំ២០១១មក។ គម្រោងនេះបានអនុវត្តសាកល្បងនៅក្នុងវិទ្យាល័យចំនួន២ និងអនុវិទ្យាល័យមួយនៅក្នុងខេត្តកំពង់ចាម។ ការផ្តួចផ្តើមនេះគឺដើម្បីដោះស្រាយបញ្ហាគុណភាព និងអភិបាលកិច្ចនៅក្នុងវិស័យអប់រំ ដែលគម្រោងអភិវឌ្ឍមុនៗមិនទាន់រកឃើញដំណោះស្រាយនៅឡើយ។ ដូចក្នុងកំណត់សម្គាល់ខាងដើម ធាតុសំខាន់មួយនៅក្នុងគំនិតផ្តួចផ្តើមនេះគឺការបង្កើនតួនាទីកាន់តែសំខាន់ដល់វិស័យ 'ឯកជន' ក្នុងដំណើរការគ្រប់គ្រងសាលារៀន ទន្ទឹមគ្នានឹងការរក្សាទំនាក់ទំនងយ៉ាងរឹងមាំជាមួយវិស័យ 'សាធារណៈ'ដូចនេះនិយមន័យគំនិតផ្តួចផ្តើមនេះគឺ ការកសាងភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP)។

កិច្ចខិតខំប្រឹងប្រែងពីមុនៗ ដើម្បីកែលម្អគុណភាពអប់រំនៅក្នុងប្រទេសកម្ពុជាបានជំរុញឲ្យបានគំរូអភិវឌ្ឍមួយដែលគេស្គាល់ថា "សាលាកុមារមេត្រី" ហើយបច្ចុប្បន្ននេះក្លាយជាគោលនយោបាយដ៏សំខាន់របស់ក្រសួងអប់រំ យុវជន និងកីឡា(MoEYS)។ BSIក៏ធ្វើការក្នុងក្របខ័ណ្ឌគោលនយោបាយសាលាកុមារមេត្រីរបស់ក្រសួងអប់រំ យុវជន និងកីឡាដែរ ប៉ុន្តែនៅក្នុងលំនាំមួយ ដែលវិស័យឯកជន(ឧ.ខេបជាភ្នាក់ងារមិនមែនរដ្ឋាភិបាល) មានឥទ្ធិពលលើការគ្រប់គ្រង និងគណនីភាពកាន់តែច្រើនជាងមុន។ នេះផ្ទុយទៅនឹងការខិតខំប្រឹងប្រែងកន្លងមកដែលបានធ្វើកិច្ចការទាំងស្រុងនៅក្នុងប្រព័ន្ធសាលារដ្ឋ ដែលជាទូទៅប្រព័ន្ធគណនីភាពមានភាពទន់ខ្សោយ។ នៅក្នុងបរិបទបែបនេះ ភ្នាក់ងារអភិវឌ្ឍដូចជាអង្គការខេបជួបការលំបាកយ៉ាងខ្លាំង ក្នុងការជះឥទ្ធិពលលើការគ្រប់គ្រងដើម្បីសម្រេចបាននូវស្នាដៃមានកម្រិតស្តង់ដារខ្ពស់ ព្រោះទីបំផុតជាទម្លាប់នាយកសាលាមិនបានទទួលខុសត្រូវលើការការបំពេញភារកិច្ចរបស់ខ្លួននោះទេ។ លំនាំបែបនេះចាក់ឬសយ៉ាងជ្រៅក្នុងប្រព័ន្ធអប់រំសព្វថ្ងៃនេះ រួមជាមួយនឹងទង្វើមិនសមស្របរបស់គ្រូទាក់ទងនឹងការតម្រូវឲ្យសិស្សបង់ថ្លៃ "មិនផ្លូវការ" ហើយប្រការនេះធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងជាពិសេសចំពោះសិស្សមកពីគ្រួសារក្រីក្រខ្លាំង។ ដោយសារតែថវិកាចំណាយមិនស្ថិតក្នុងក្របខណ្ឌច្បាប់ (ខុសពីការអនុវត្តនៅតាមសាលាឯកជន) វាមានផលជះតិចតួចទៅលើគុណភាពអប់រំក្នុងសាលារៀន។ ខណៈគម្រោងមុនៗដែលផ្តោតការយកចិត្តទុកដាក់លើគោលការណ៍សាលាកុមារមេត្រីបានសម្រេចជោគជ័យក្នុងកម្រិតមួយ ដោយបានដោះស្រាយនូវបញ្ហាមួយចំនួនដូចជា ការកែលម្អការទទួលបានសេវា អប់រំ និងហេដ្ឋារចនាសម្ព័ន្ធយ៉ាងណាក្តី ក៏គម្រោងភាគច្រើនហាក់ដូចជាឈប់ទ្រឹងមួយកន្លែងទៅមុខលែងរួចទាក់ទងនឹងគុណ

ភាពអប់រំ។

## 1.3 ការវិវឌ្ឍបច្ចុប្បន្នឆ្ពោះទៅរកភាពជាដៃគូរវាងរដ្ឋ និងឯកជន

ដោយសារតែនៅក្នុងប្រវត្តិសាស្ត្រ រដ្ឋជំទាស់នឹងគំនិតដែលចង់បង្កើតឲ្យមានការអប់រំឯកជននៅក្នុងប្រទេសកំពុងអភិវឌ្ឍមួយចំនួននៅក្នុងអាស៊ីប៉ាស៊ីហ្វិក(EAPR) ប្រការនេះហាក់កំពុងមានការផ្លាស់ប្តូរ។ ប្រទេសជាច្រើននៅក្នុងតំបន់កំពុងតែធ្វើការផ្លាស់ប្តូរឲ្យមានទំនាក់ទំនងរវាងប្រព័ន្ធអប់រំរដ្ឋ និងឯកជន ក្នុងនោះរដ្ឋផ្តល់នូវក្របខ័ណ្ឌគតិយុត្តិកាន់តែច្រើនជាងមុន ចំណែកវិស័យឯកជនដើរតួនាទីកាន់តែសំខាន់ក្នុងការផ្តល់សេវាអប់រំ។ និន្នាការទាំងនេះកំពុងត្រូវបានលើកទឹកចិត្តដោយស្ថាប័នអភិវឌ្ឍធំៗដូចជា UNICEF និងធនាគារអភិវឌ្ឍអាស៊ី (ADB) ដោយស្ថាប័នទាំងពីរនេះបានរៀបចំសិក្ខាសាលាថ្នាក់តំបន់ស្តីអំពីភាពជាដៃគូរវាងរដ្ឋ និងឯកជននៅក្នុងឆ្នាំ២០១០ ដែលតាមរយៈសិក្ខាសាលានេះ គេបានសង្កេតឃើញថា:

> បណ្តាប្រទេសជាច្រើនទៀតទទួលស្គាល់អត្ថិភាពនៃភ្នាក់ងារឯកជន និងផលប្រយោជន៍នៃការប្រើប្រាស់អ្នកផ្តល់សេវាឯកជន(NSPs)សម្រាប់ជំរុញឲ្យជឿនលឿននូវគោលដៅអប់រំជាតិ និងចំណុចអាទិភាពនានា។ ភាពជាដៃគូរវាងរដ្ឋ និងឯកជន(PPPs)ជាមួយនឹងអ្នកផ្តល់សេវាមិនមែនរដ្ឋ(NSPs)គឺមានទម្រង់ច្រើន តែមានគោលដៅរួមដូចគ្នា ពោលគឺការពង្រឹងគុណភាពអប់រំសម្រាប់ទាំងអស់គ្នា ព្រមគ្នានឹងការកាត់បន្ថយការចំណាយ។ នៅក្នុងគោលការណ៍ភាពជាដៃគូរវាងរដ្ឋ និងឯកជន(PPPs) វិស័យសាធារណៈកំណត់វិសាលភាពនៃលទ្ធផល ចំណែកវិស័យឯកជនទទួលបន្ទុកផ្តល់សេវាកម្ម (UNICEF-ADB,2010) [3]។

ដូចនេះ**ការទទួលយករបស់រដ្ឋាភិបាលក្នុងតំបន់ដើម្បីបង្កើតឲ្យមានភាពជាដៃគូរវាងរដ្ឋ និងឯកជនហាក់ដូចជាកំពុងតែកើនឡើង**។ នេះគឺជាការពិតនៅក្នុងប្រទេសកម្ពុជាដែលទាំងអាជ្ញាធរអប់រំនៅមូលដ្ឋាន និងថ្នាក់ដឹកនាំក្រសួង(ថ្នាក់ជាតិ)បានសម្តែងការចាប់អារម្មណ៍ក្នុងការធ្វើការងារជាមួយអង្គការខេប ដើម្បីអភិវឌ្ឍន៍គំរូនៃភាពជាដៃគូរវាងរដ្ឋ និងឯកជនដែលជួយបង្កើនគុណភាពអប់រំនៅក្នុងប្រព័ន្ធអប់រំរដ្ឋ។

មានករណីជាច្រើនដែលឆន្ទៈនេះនាំមកនូវហានិភ័យដ៏ធំៗមួយចំនួន ហើយថាតើសាធារណជននឹងប្រតិកម្មយ៉ាងណាចំពោះហានិភ័យនេះ។ ហានិភ័យទាំងនោះត្រូវបានចែករំលែករួមគ្នារវាងរដ្ឋាភិបាល និងអង្គការខេប។

ទោះបីនៅពេលនេះហាក់ដូចជាពេលវេលាសមស្របសម្រាប់បង្ហាញពីគំរូនៃការអភិវឌ្ឍការអប់រំដែលប្រើវិធីសាស្ត្រ PPP យ៉ាងណាក៏ដោយ ខេបបានចាប់យកកិច្ចការទាំងនេះទាំងដឹងច្បាស់ថា បញ្ញត្តិទាំងនេះគឺនៅថ្មីស្រឡាងសម្រាប់ប្រទេសកម្ពុជា ដែលប្រព័ន្ធអប់រំរដ្ឋ និងឯកជនជាទូទៅញែកដាច់ពីគ្នា។ សូម្បីតែនៅក្នុងចំណោមអ្នកឯកទេសអភិវឌ្ឍន៍ បញ្ញត្តិជាច្រើនទាក់ទងនឹង PPP គឺនៅតែប្រៀបបាននឹងអង្គធាតុរាវដែលងាយប្រែប្រួល ដូច្នេះមាននិយមន័យខុសៗគ្នាជាច្រើនចំពោះអ្វីទៅភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងបរិបទផ្សេងគ្នា។ ឧទាហរណ៍ដៃគូអភិវឌ្ឍន៍ជាច្រើនបានបដិសេធន៍គំនិតដែលចាត់ទុកអង្គការក្រៅរដ្ឋាភិបាលគឺជា 'ស្ថានប័នឯកជន' ដោយសារតែជាទូទៅអង្គការមិនមែនរដ្ឋាភិបាលជាស្ថាប័ន

[3] *Delivering Education Services to the Poor- What Role for the Non-State Sector?,* Position Paper prepared for UNICEF-ADB Workshop on "The Role of Non-State Providers in Delivering Basic Social Services for Children," Manila, April 2010.

មិនរកប្រាក់កំរៃប្រតិបត្តិការនៅក្នុងវិស័យសាធារណៈ។ អ្នកផ្សេងទៀតរួមទាំងក្រុមបច្ចេកទេសរបស់ខេបជឿជាក់ថា អង្គការណាក៏ដោយ ដែលមិនមែនជារបស់រដ្ឋ ដោយមានទិសដៅខ្លួនឯងគឺអាចរាប់ថាជាស្ថាប័នឯកជន។ **ផ្ទុយទៅវិញការរកឃើញថ្មី និងភាពស្វាហាប់នៃវិធីសាស្ត្រក្នុងវដ្តអភិវឌ្ឍន៍នេះបានបង្ហាញថា BSIបានបង្កើតឲ្យមានការរកឃើញថ្មីមួយ នៅក្នុងវិស័យអប់រំប្រទេសកម្ពុជា និងពង្រីកការយល់ដឹងរបស់យើងស្តីអំពីការអភិវឌ្ឍវិស័យអប់រំនៅតាមលំនាំថ្មីៗ ដែលមិនធ្លាប់មានពីមុនមក។** ហេតុដូច្នេះការគាំទ្ររបស់ម្ចាស់ជំនួយចំពោះគំនិតផ្តួចផ្តើមថ្មីនេះបានរួមចំណែកយ៉ាងច្រើនដល់សមត្ថភាពកម្ពុជាខ្លួនឯង ដើម្បីរៀបចំ និងសម្រេចបាននូវសមិទ្ធិផលរូបីផ្នែកគុណភាពអប់រំនៅតាមសាលារៀនដែលបានជ្រើសរើស។ លក្ខណៈទាំងនេះជាភស្តុតាងដែលបញ្ជាក់ពីឈ្មោះនៃគំនិតផ្តួចផ្តើមថ្មី ថាគំនិតមួយក្នុងការស្វែងរកឲ្យបាននូវការដើរតួជា 'ប្រទីបបំភ្លឺផ្លូវ' សម្រាប់ការអភិវឌ្ឍវិស័យអប់រំនាពេលអនាគត។

## 2. ការវិភាគបញ្ហាដែលជាមូលដ្ឋានក្នុងការបង្កើតគម្រោងសាលារៀនដៃគូ

### 2.1 បញ្ហាទូទៅដែលធ្វើឲ្យគុណភាពអប់រំចុះខ្សោយ

ការពិពណ៌នាអំពីប្រវត្តិដើមដែលបានរៀបរាប់ខាងលើធ្វើឲ្យកាន់តែច្បាស់ថា មានតម្រូវការចាំបាច់ខ្លាំងក្នុងការផ្តោតការយកចិត្តទុកដាក់ទៅលើគុណភាពអប់រំ។ តម្រូវការនេះបានផ្តល់សនិទានភាពសម្រាប់គម្រោងតូចមួយ ប៉ុន្តែយកចិត្តទុកដាក់ខ្លាំងដូចជាគម្រោងBSI ដែលបានឈានផុតទៅមុខលើសពីគំរូអភិវឌ្ឍន៍នានាកន្លងមក។ ទន្ទឹមនឹងនេះ គម្រោងក៏មានគោលបំណងជួយសកម្មភាពសាលាកុមារមេត្រី ដើម្បីដោះស្រាយបញ្ហារ៉ាំរ៉ៃនៅក្នុងប្រព័ន្ធសាលារៀនរដ្ឋ ដែលធ្វើឲ្យគុណភាពអប់រំចុះខ្សោយ។ បញ្ហាទាំងអស់នេះជាបញ្ហារួមរបស់សាលារៀនរដ្ឋក្នុងបណ្តាប្រទេសផ្សេងទៀតដែររួមមាន (i)ផ្នែកគណនេយ្យភាពក្នុងការបំពេញភារកិច្ចនៅមានកម្រិតទាបទាំងសហគមន៍ និងមន្ត្រីអប់រំស្រុក (ii)ភាពអន់ថយក្នុងការកំណត់និយមន័យច្រកអាជីពសម្រាប់បុគ្គលដែលមានស្តង់ដាវិជ្ជាជីវៈខ្ពស់(មានផលវិបាកក្នុងការលើកទឹកចិត្ត) និង(iii)ប្រាក់រង្វាន់លើកទឹកចិត្តតិចតួច។ បើប្រៀបធៀបជាមួយសាលាឯកជននៅក្នុងប្រទេសកម្ពុជា ដែលឪពុកម្តាយបានបង់ថ្លៃសាលាទាមទារនូវការអប់រំប្រកបដោយស្តង់ដាខ្ពស់ នោះសាលារដ្ឋនៅក្នុងប្រទេសកម្ពុជាកំពុងក្លាយជាទីកន្លែងចុងក្រោយតែមួយគត់សម្រាប់សិស្សក្រីក្រដែលមានចំនួនកាន់តែច្រើន ជាពិសេសគឺនៅតំបន់ទីប្រជុំជន។

ការទទួលស្គាល់ពីតម្រូវការនៃវិធីសាស្ត្រដើម្បីកែលម្អគុណភាពអប់រំនៅក្នុងប្រទេសកម្ពុជាមិនមែនជារឿងថ្មីថ្មោងនោះទេ និងទាំងអ្នកឯកទេសអប់រំជាតិ និងអន្តរជាតិបាន និងកំពុងពិភាក្សាអស់រយៈកាលយូរមកហើយ។ ទោះជាយ៉ាងនេះក្តី មានការមូលមតិគ្នាកាន់តែច្រើនលើចំណុចមួយចំនួនថា យុទ្ធសាស្ត្រទាំងនោះដែលផ្តោតទាំងស្រុងទៅលើសាលារដ្ឋដោយមិនយោងលើវិស័យឯកជនកំពុងក្លាយជាយុទ្ធសាស្ត្រមិនសូវសមស្របបន្តិចម្តងៗ សម្រាប់ធ្វើឲ្យសម្រេចបាននូវសមិទ្ធិផលធំផ្នែកកែលម្អគុណភាពអប់រំ។ នេះមួយផ្នែកធំដោយសារតែកង្វះអភិបាលកិច្ចល្អក្នុងវិស័យអប់រំសាធារណៈជាការបាត់បង់មូលដ្ឋានគ្រឹះជាយូរមកហើយសម្រាប់ការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព(មើលខាងក្រោម)។ នោះគឺវិស័យសាធារណៈដែលខ្វះទម្លាប់មឹងម៉ាត់ក្នុងការធ្វើឲ្យគ្រូបង្រៀន និងនាយកសាលាមានការទទួលខុសត្រូវចំពោះប្រសិទ្ធភាព

នៃការផ្តល់សេវាអប់រំ លើកលែងតែក្នុងស្ថានភាពធ្ងន់ធ្ងរខ្លាំង។

ចំនួនសាលាឯកជនបានរីកដុះដាលនៅក្នុងប្រទេសកម្ពុជាមិនត្រឹមតែនៅរាជធានីភ្នំពេញទេ ប៉ុន្តែក៏មាននៅតាមខេត្តជាច្រើនដូចជាកំពង់ចាមជាដើម។ ជាលើកដំបូងហើយក្នុងប្រវត្តិសាស្ត្រកម្ពុជាប្រជាជនទូទៅឥឡូវនេះមានជម្រើសចំពោះសាលារៀនរដ្ឋ យ៉ាងហោចណាស់នៅតាមទីប្រជុំជន។ ទោះជាយ៉ាងនេះក្តី សាលាឯកជនជាទូទៅមិនបានផ្តល់សមធម៌សម្រាប់ការចូលរៀនដល់អ្នកក្រីក្រនៅតំបន់ដាច់ស្រយាល និងនៅទីប្រជុំជនទេ ហើយមានទំនាក់ទំនងតិចតួចជាមួយវិស័យសារធារណៈ ទោះក្នុងករណីណាក៏ដោយ[4]។ ទោះបីជាមានចលនារីកចម្រើនគួរកត់សម្គាល់ក្នុងវិស័យអប់រំសាធារណៈ ដោយមានការកែលម្អហេដ្ឋារចនាសម្ព័ន្ធ កម្មវិធីសិក្សា និងធនធានសម្ភារៈកើនឡើងយ៉ាងណាក្តី កង្វះខាតអភិបាលកិច្ចល្អ ជាពិសេសក្នុងចំណោមនាយកសាលា និងគ្រូបង្រៀន មានន័យថាការប្រើប្រាស់ធនធានបានផ្តល់ ក្នុងតម្លៃយ៉ាងច្រើនដោយម្ចាស់ជំនួយ មានប្រសិទ្ធភាពតិចតួចបំផុត។ ស្ថានភាពនេះធ្វើឲ្យគុណភាពអប់រំធ្លាក់ចុះយ៉ាងខ្លាំង។

## 2.2 បញ្ហាគណនីយភាព

អភិបាលកិច្ចទន់ខ្សោយឆ្លុះឲ្យឃើញថា*ខ្វះគណនីយភាព*ក្នុងការបំពេញភារកិច្ច ដែលនាំឲ្យមានការអនុគ្រោះខ្ពស់ចំពោះទង្វើខ្វះវិជ្ជាជីវៈ ឬសូម្បីទង្វើអសមត្ថភាព។ ការធ្វើឲ្យគ្រូបង្រៀន នាយកសាលា និងបុគ្គលិកអប់រំសំខាន់ៗប្រកាន់ខ្ជាប់នូវការបំពេញភារកិច្ចតាមស្តង់ដារកំណត់ជាការលំបាកណាស់ នៅពេលដែលមានការលើកទឹកចិត្តតិចតួចសម្រាប់អ្នកបំពេញការងារវិជ្ជាជីវៈបានល្អ និងមានការដាក់ទណ្ឌកម្មតិចតួចចំពោះអ្នកមិនយកចិតទុកដាក់ក្នុងការបំពេញភារកិច្ច។ លទ្ធផលនៃស្ថានភាពនេះបង្ហាញថាសម្ភារៈ ឬធនធានដែលបានផ្តល់ឲ្យ ជារឿយៗមានការប្រើប្រាស់តិចតួច ឬមិនមានការប្រើប្រាស់តែម្តង។ មានឧទាហរណ៍ទូទៅជាច្រើនស្តីពីលទ្ធផលបែបនេះ។ ឧទាហរណ៍គ្រូបង្រៀនជាច្រើនមានអារម្មណ៍ថាពួកគាត់មិនស្ថិតនៅក្រោមការតម្រូវដាច់ខាតឲ្យអនុវត្តវិធីសាស្ត្រថ្មីដែលទទួលបានពីការបណ្តុះបណ្តាល ឬប្រើសម្ភារៈឧបទេសដែលបានទទួលសម្រាប់ការរៀនសូត្រ បណ្ណាល័យដែលបានជួសជុលហើយនៅតែចាក់សោរ ហើយមិនបានបម្រើសេចក្តីត្រូវការដល់សិស្ស ប្រព័ន្ធទឹកមិនមានការថែទាំ ហើយទីបំផុតត្រូវបោះបង់ចោលឈប់ប្រើ និងមិនថែទាំ ឬសម្ភារៈIT ត្រូវខូចខាតយ៉ាងរហ័សដោយសារតែខ្វះការថែរក្សា និងប្រើប្រាស់។ ប៉ុន្តែបញ្ហាមួយចំនួនខាងលើនេះ គម្រោងអភិវឌ្ឍន៍បានជួយជាច្រើនឆ្នាំមកហើយ។ តាមពិតទៅក៏មានបុគ្គល និងសាលារៀនមួយចំនួនដែលបានបង្ហាញឲ្យឃើញថាមានស្តង់ដារវិជ្ជាជីវៈខ្ពស់ ប៉ុន្តែធម្មតាប្រការនេះបានកើតឡើងមិនមែនដោយសារតែការបង្ខំណាមួយ ឬដាក់កំហិតដោយប្រព័ន្ធអប់រំនោះទេ។ ក្នុងនេះមានបញ្ហាគន្លឹះមួយក្នុងការអនុវត្តកម្មវិធីសាលាកុមារមេត្រីថ្នាក់ជាតិ នោះគឺភាពខុសប្លែកគ្នាខ្លាំងក្នុងចំណោមបុគ្គលិកអប់រំ ក្នុងន័យប្រកាន់ខ្ជាប់ស្តង់ដារវិជ្ជាជីវៈ និងអសមត្ថភាពនៃប្រព័ន្ធអប់រំសាធារណៈដើម្បីអនុវត្តស្តង់ដារឲ្យបានទូលំទូលាយ ដែលធ្វើឲ្យការអភិវឌ្ឍប្រកបដោយអត្ថន័យពេញលេញមានការធ្លាក់ចុះ។

[4] KAPE (2013) *Enrollment Trends in Phnom Penh: A Need Assessment,* Phnom Penh: Save the Children

## 2.3 ច្រកអាជីព និងប្រាក់លើកទឹកចិត្តស្តួចស្តើង

ទាក់ទងទៅនឹងអ្វីដែលរៀបរាប់ខាងលើគឺជាបញ្ហាច្រកអាជីពសម្រាប់បុគ្គលបម្រើការងាររដ្ឋដែលបានបង្ហាញនូវឥរិយាបថវិជ្ជាជីវៈល្អ។ និយាយឲ្យខ្លីមានច្រកអាជីពបែបនេះតិចតួចណាស់សម្រាប់គ្រូបង្រៀន និងនាយកសាលាឆ្នើមបំផុតក្នុងប្រព័ន្ធអប់រំសាធារណៈនៅក្នុងប្រទេសកម្ពុជា។ ដូចនេះប្រព័ន្ធជាក់លាក់មួយក្នុងការបន្តផ្តល់រង្វាន់ (ឧ. អាហារូបករណ៍សម្រាប់បន្តការសិក្សា កុំព្យូទ័រយួរដៃ និងឱកាសសម្រាប់ការអភិវឌ្ឍ) ដែលទទួលស្គាល់ពីឥរិយាបថវិជ្ជាជីវៈគឺពិតជាត្រូវការចាំបាច់ដើម្បីធានាបាននូវការបន្តលើកទឹកចិត្ត និងគុណភាពនៅតាមសាលារៀនគោលដៅ។



ការប្រជុំជាមួយគ្រូដើម្បីតាមដានលើផែនការ និងការឆ្លុះបញ្ចាំងពីកំណត់ត្រា

ការផ្សារភ្ជាប់នឹងប្រាក់រង្វាន់តិចតួច (ពេលខ្លះមិនទៀងទាត់) ក៏ដូចជារចនាសម្ព័ន្ធគណនីភាពទន់ខ្សោយនៅក្នុងប្រព័ន្ធអប់រំ គ្មានការលើកទឹកចិត្តផ្តល់ច្រកអាជីព ដែលធ្វើឲ្យស្តង់ដារវិជ្ជាជីវៈទាបនៅទូទាំងប្រព័ន្ធអប់រំនៅកម្ពុជា។

## 2.4 ភាពចាំបាច់ក្នុងការបង្កើតសាលាជំនាន់ថ្មីដែលមានស្តង់ដារ "អតិបរមា"

គម្រោងសាលារៀនដៃគូបានជួបការលំបាកជាមួយនឹងសញ្ញាណ "ស្តង់ដាអប្បរមា" ជាគំរូកណ្តាលដែលជាញឹកញាប់ជាមូលដ្ឋានគ្រឹះសម្រាប់គម្រោងអភិវឌ្ឍន៍ជាច្រើន។ នោះមានន័យថា គម្រោងអភិវឌ្ឍន៍ជាច្រើនដែលគ្រាន់តែស្វែងរកការបង្កើនគុណភាពអប់រំដោយធ្វើឲ្យសាលារៀននោះក្លាយជាសាលាកម្រិតស្តង់ដាអប្បរមា ធានាបានថាសាលារៀនប្រកាន់ខ្ជាប់នូវស្តង់ដារ "កម្រិតទាបបំផុត"អនុញ្ញាតដោយច្បាប់។ នោះគឺជាដំណើរស្វែងរកស្តង់ដាអប្បរមាប្រៀបបាននឹងអន្ទាក់ដែលរារាំងសាលារៀនជាច្រើននៅក្នុងប្រព័ន្ធអប់រំរដ្ឋពីការសម្រេចបានស្តង់ដាអប់រំខ្ពស់។ ហេតុនេះ BSI បានធ្វើការសម្រេចចិត្តប្រើយុទ្ធសាស្ត្រផ្តោតទៅលើស្តង់ដារអតិបរមា ដែលផ្ទុយនឹងស្តង់ដាអប្បរមា និងការធ្វើវិនិយោគស្របនឹងគោលបំណងនេះ។ គោលបំណងឲ្យមានស្តង់ដាអតិបរមា គម្រោងបានសន្មត់យ៉ាងច្បាស់ថាទោះបីគំរូនេះមិនអាចត្រូវបានគេចម្លងនៅគ្រប់ទីកន្លែងយ៉ាងណាក៏ដោយ វាអាចត្រូវបានចម្លងនៅក្នុងកន្លែងជាច្រើនដែលមានធនធាន និងការគ្រប់គ្រងត្រឹមត្រូវល្អ។ គម្រោងនេះបានបដិសេធន៍គំនិតដែលថា គំរូដែលមិនអាចត្រូវបានគេចម្លងគ្រប់ទីកន្លែងមិនសមនឹងទទួលបាននូវការគាំទ្រ និងស្នើសុំជំនួសដោយទស្សនៈការអភិវឌ្ឍច្រើនបែប(*multiple development tracks*)ដែលធានាថាយ៉ាងហោចណាស់សាលារៀនរដ្ឋមួយចំនួនអាចសម្រេចបានស្តង់ដាការអប់រំល្អឈានមុខគេ។ សាលារៀនដែលសម្រេចបានស្តង់ដាបែបនេះអាចដើរតួជា**សាលារៀនជំនាន់ថ្មី**ដែលផ្តល់ស្តង់ការអប់រំខ្ពស់ដល់កុមារគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម និងមិនមែនសម្រាប់តែសិស្សមួយចំនួនតូចដែលមានបុព្វសិទ្ធិចូលរៀននៅសាលាឯកជននោះទេ។

## 3. បទពិសោធន៍ដ៏ធំមួយក្នុងអនុវត្តការបង់ថ្លៃសិក្សាដើម្បីធានានិរន្តរភាពគុណភាពអប់រំ និងលុបបំបាត់អំពើពុករលួយ

### 3.1 ជំហានទីមួយ៖ ការបង្កើតគំរូនៃគុណភាព "អតិបរមា"

**ការជំរុញនៃតម្រូវការ៖** គម្រោងBSI រំពឹងទុកមុនតាំងពីដើមទីមកថា ការគាំទ្រហិរញ្ញវត្ថុពីឪពុកម្តាយសិស្សទំនងជានឹងក្លាយជាយុទ្ធសាស្ត្រដ៏សំខាន់សម្រាប់ទ្រទ្រង់នូវគំរូអភិបាលកិច្ចថ្មីមួយ ផ្សារភ្ជាប់នឹងស្តង់ដារការអប់រំខ្ពស់។ ការកើនឡើងយ៉ាងឆាប់រហ័យនូវចំនួនសាលាឯកជនគឺជាភស្តុតាងបង្ហាញថាឪពុកម្តាយជាច្រើនមានឆន្ទៈចំណាយថវិកាទៅលើសេវាអប់រំមានគុណភាពខ្ពស់។





មុន និងក្រោយ កាលពីមុននិងក្រោយសាលាអនុវត្តបានប្រែក្លាយទៅជាសាលាជំនាន់ថ្មី

ដូចច្នេះគម្រោងនេះបានស្វះស្វែង រៀបចំឲ្យមានស្តង់ដារអប់រំខ្ពស់ដំបូងគេនៅតាមសាលាគោលដៅរបស់ខ្លួនដែលជាជំហានទីមួយក្នុងការអនុវត្ត។ សាលាមួយក្នុងចំណោមសាលាផ្សេងទៀតដែលបានជ្រើសរើសសម្រាប់ការខិតខំនេះគឺជាសាលាដែលហៀបនឹងដួលទៅហើយ និងមានទីតាំងនៅក្នុងទីរួមខេត្ត។ សាលាដែលសាងសង់សម្រាប់ទទួលសិស្សបាន ៨០០នាក់ ប៉ុន្តែចំនួនសិស្សបានធ្លាក់ចុះមកសល់ត្រឹមតែ៥០នាក់ប៉ុណ្ណោះដោយសារស្តង់ដារអប់រំបានធ្លាក់ចុះដល់បាត ដែលនេះជាភស្តុតាងស្រាប់។ សាលានេះគឺស្ទើរតែត្រូវបិទទ្វារទៅហើយ។ សាលាពីរផ្សេងទៀតគឺជាសាលាលំដាប់មធ្យម និងធំជាងសាលាទីមួយ។ ក្នុងចំណោមសាលាទាំងពីរនេះ មួយមានទីតាំងនៅពាក់កណ្តាលទីប្រជុំជន និងជនបទ ឯសាលាមួយទៀតគឺស្ថិតនៅតំបន់ជនបទទាំងស្រុង។

**ការរៀបចំរចនាសម្ព័ន្ធអភិបាលកិច្ចថ្មី និងការជ្រើសរើសគ្រូ៖**គម្រោងបានចាប់ផ្តើមដំណើរការវិនិយោគ មិនគ្រាន់តែទៅលើហេដ្ឋារចនាសម្ព័ន្ធ គ្រឿងសង្ហារឹម និងបរិក្ខារសំខាន់ៗប៉ុណ្ណោះទេ ប៉ុន្តែក៏វិនិយោគទៅលើបែបបទគ្រប់គ្រងសាលារៀនផងដែរ។ ក្រុមប្រឹក្សាភិបាលដែលមានសមាភាពមកពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងមន្ត្រីអង្គការខេបត្រូវបានបង្កើតឡើងដើម្បីធានាឲ្យបាននូវគណនីយភាពសម្រាប់បុគ្គលិកសាលារៀនទាំងនោះក្នុងបំពេញភារ

កិច្ចក្នុងសាលា។

*គំរូនៃការគ្រប់គ្រងចំរុះ*ផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយប្រព័ន្ធផ្តល់ថវិកាលើកទឹកចិត្តបន្ថែម តាមការបំពេញភារកិច្ចសម្រាប់នាយកសាលាដែលត្រូវធានាឲ្យបាននូវគណនីយភាពចំពោះក្រុមប្រឹក្សាភិបាល។ សម្រាប់សាលាអនុវត្ត គ្រូបង្រៀនថ្មីៗត្រូវបានជ្រើសរើសតាមរយៈការប្រកួតប្រជែងសមត្ថភាព និងតម្លាភាពដោយក្រុមប្រឹក្សាភិបាលដើរតួជាគណៈកម្មការសម្ភាសន៍។ ដោយសារការិយាល័យបុគ្គលិករបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តក៏ជាសមាជិកក្រុមប្រឹក្សាភិបាលដែរនោះ ធ្វើឲ្យក្រុមប្រឹក្សាភិបាលបានសម្របសម្រួលយ៉ាងច្រើនមហិមាក្នុងកិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ។ វិធីជ្រើសរគ្រូបង្រៀនថ្មីៗបែបនេះបានបង្ហាញឲ្យឃើញនូវការចាប់ផ្តើមគួរឲ្យកត់សម្គាល់មួយខុសពីការអនុវត្តបែបសាមញ្ញៗនៃយន្តការការចាត់តាំង ទៅជាការជ្រើសរើសផ្អែកតាមលក្ខណៈសម្បត្តិ។ គ្រូបង្រៀនថ្មីៗត្រូវបានជ្រើសរើសតាមរយៈការពិនិត្យមើលចំណាប់អារម្មណ៍លើការអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈ។ នៅក្នុងការសម្ភាសជ្រើសរើសើ បំណងរបស់គ្រូដែលចង់ឲ្យសិស្សបង់ថ្លៃ "រៀនគួរ" ហើយត្រូវជំនួសដោយប្រាក់ឧបត្ថម្ភបន្ថែមលើប្រាក់ខែត្រូវបានយកមកវាយតម្លៃផងដែរ។ ជាអកុសលគម្រោងពុំទាន់មានលទ្ធភាពផ្លាស់ប្តូរដូចគ្នានេះបានទេសម្រាប់បុគ្គលិកសិក្សានៅសាលាពីរទៀតដោយសារតែសាលាទាំងនោះជាសាលាចាស់ និងជាសាលាធំដែលមានគ្រូបង្រៀនជាច្រើនរួចស្រេចទៅហើយ (ស្តង់ដាវិជ្ជាជីវៈមានអថេរខ្ពស់) ។

**ការអភិវឌ្ឍច្រកអាជីពសម្រាប់គ្រូបង្រៀនៈ** ទោះបីជាគ្រូបង្រៀនបានទទួលប្រាក់លើកទឹកចិត្តបន្ថែមអាស្រ័យការបំពេញកិច្ចការពិសេសបានអនុវត្ត វាសំខាន់ស្មើគ្នា ដែលគ្រូៗទើបត្រូវបានជ្រើសរើសថ្មីៗត្រូវវាយតម្លៃខ្ពស់មិនមែនតែទៅលើការលើកទឹកចិត្តផ្អែកថវិកាតែមួយមុខនោះទេ ប៉ុន្តែគាត់ត្រូវឲ្យតម្លៃទៅលើការទទួលនូវបានការពង្រឹងវិជ្ជាជីវៈគ្រូបង្រៀនទៀតផង ។



ការបង្កើតមណ្ឌលព័ត៌មានៈ សិស្សបានកំពុងទស្សនាភាពយន្តឯកសារដែលជាផ្នែកមួយនៃមេរៀនប្រចាំថ្ងៃ

អាហារូបករណ៍ និងកុំព្យូទ័រយួរដៃត្រូវបានផ្តល់ជូនដល់គ្រូបង្រៀនគ្រប់រូបដើម្បីជាការលើកទឹកចិត្តគាត់ក្នុងនាមជាគ្រូបង្រៀនក៏ដូចជាសមត្ថភាពអាជីព។ គម្រោងបានរៀបចំការជួបប្រជុំប្រចាំខែជាមួយគ្រូបង្រៀនដើម្បីកំណត់គោលដៅអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងដើម្បីត្រួតពិនិត្យគោលដៅទាំងនោះឡើងវិញជាទៀងទាត់។ គ្រូដែលមានឆន្ទៈចង់ធ្វើការងារបន្ថែម (ឧ. ដឹកនាំក្លិបមុខវិជ្ជា រៀបចំទស្សនៈកិច្ចសិក្សា...ល។)

បានទទួលប្រាក់លើកទឹកចិត្តកាន់តែច្រើន។

**ការប្រើប្រាស់បច្ចេកវិទ្យា៖** ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការសិក្សាផ្សារភ្ជាប់ជាមួយវិធីសាស្ត្របង្រៀនបែបស្ថាបនា បានបង្ហាញភាពលេចធ្លោសម្រាប់ជាមធ្យោបាយក្នុងការលើកកម្ពស់គុណភាពនៃការបង្រៀន និងរៀន។ ប្រការនេះតម្រូវឲ្យមានការបង្កើតបន្ទប់ព័ត៌មានវិទ្យាICT មណ្ឌលព័ត៌មាន ការប្រើប្រាស់ទូរទស្សន៍ និងឧបករណ៍អេឡិចត្រូនិចtablets អមជាមួយកុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងLCD ព្រមទាំងបណ្ណាល័យដែលមានភ្ជាប់សេវាអ៊ីនធឺណេត។ គ្រូបង្រៀនបានទទួលការបំប៉នសមត្ថភាពប្រើប្រាស់ឧបករណ៍ទាំងអស់នេះក្នុងការបង្រៀន រួមទាំងការប្រើ Power Point សម្រាប់ធ្វើបទបង្ហាញមេរៀន កម្មវិធីសម្រាប់ធ្វើកិច្ចតែងការបង្រៀន និងភាពយន្តឯកសារដែលជាផ្នែកបន្ថែមជួយគាំទ្រដល់ដំណើរការបង្រៀន។ ការប្រើប្រាស់បច្ចេកវិទ្យាទាំងអស់នេះមិនគ្រាន់តែធ្វើឲ្យប្រសើរឡើងលើការបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាកត្តាលើកទឹកចិត្តដ៏ធំមួយសម្រាប់សិស្ស និងកែលម្អទស្សនៈរបស់មាតាបិតាសិស្ស និងសមាជិកសហគមន៍ចំពោះសាលារៀនទៀតផង។

**តួនាទីស្ថាបត្យកម្មអគារសិក្សាថ្មីក្នុងការធ្វើឲ្យទាន់សម័យៈ** កត្តាសំខាន់មួយទៀតនៃកិច្ចខិតខំប្រឹងប្រែងរបស់BSI ដើម្បីកែលម្អស្តង់ដារអប់រំគឺទាក់ទងនឹងការសម្រេចចិត្តងាកចេញពីគំរូអគារសិក្សាចាស់ ដែលត្រូវបានប្រើប្រាស់នៅក្នុងប្រព័ន្ធអប់រំចាប់តាំងពីសម័យអាណានិគមបារាំងមក។ ការប្រើប្រាស់ស្ថាបត្យកម្មច្នៃប្រឌិតថ្មី ដែលកំពុងតែកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងប្រទេសជាច្រើនទៀត សំដៅកែលម្អសោភណភាពបរិស្ថានសិក្សា ហើយការផ្លាស់ប្តូរបែបនេះមានភាពឃើតយ៉ាវគួរឲ្យសោកស្តាយសម្រាប់សាលារៀនប្រទេសកម្ពុជា ដែលត្រូវបានមើលឃើញជាទូទៅថាគ្មានភាពទាក់ទាញ និងខ្វះសោភណភាព។

សាលារៀនBSI មានដាក់កញ្ចក់យ៉ាងច្រើន ប្លែកពីសម្ភារៈសំណង់ចាស់ មានសួនច្បារនៅខាងក្នុងអគារ និងមានកន្លែងសិក្សាបន្ថែមក្នុងបន្ទប់ ដើម្បីបង្កើនបរិស្ថានសិក្សា។ ការវិនិយោគនេះបានកែលម្អសោភណភាពយ៉ាងច្រើនដល់បរិស្ថានសាលារៀន ហើយក៏បានបង្ហាញឲ្យឃើញថាមានតម្លៃថោកជាងអគារស្តង់ដារដែលជិតខាងជាច្រើនសាងសង់ដោយធនាគារអភិវឌ្ឍអន្តរជាតិ។ ដូចនេះការប្រើស្ថាបត្យកម្មច្នៃប្រឌិតថ្មីបានក្លាយជាយុទ្ធសាស្ត្រគន្លឹះក្នុងការកែលម្អរូបរាងសាលារៀនស្របនឹងបំណងប្រាថ្នា និងជាការលើកទឹកចិត្តទាំងសិស្ស និងគ្រូឲ្យចង់មកសាលា។ ជាការពិតណាស់គ្រូភាគច្រើនបានបង្ហាញថា មានការពេញចិត្តនឹងបរិស្ថានសាលារៀនជាងបរិស្ថានជុំវិញលំនៅដ្ឋានរបស់គាត់ផ្ទាល់ ហើយជាញឹកញាប់គាត់បានមកលេងសាលានៅចុងសប្តាហ៍ ឬនៅម៉ោងទំនេរពីការងារ។



**ប្លង់ស្ថាបត្យកម្មថ្មីដើម្បីលើកស្ទួយបរិស្ថានសិក្សា:** អគារសិក្សាថ្មីដែលប្រើប្រាស់កញ្ចក់ច្រើន និងសួនច្បារ បើប្រៀបធៀបជាមួយសាលាធម្មតាមគឺមិនអាចធ្វើបានទេ

## 3.2 ការធានានិរន្តរភាពនូវគំរូថ្មី

**បញ្ហាប្រឈមៈ** បន្ទាប់ពីប្រតិបត្តិការអស់រយៈពេល៣ឆ្នាំកន្លងមក ទស្សនៈរបស់សហគមន៍ទៅលើគុណភាពអប់រំដែលយ៉ាងហោចណាស់នៅក្នុងសាលារៀនពីររបស់គម្រោង មានភាពប្រសើរឡើងគួរឲ្យកត់សម្គាល់។ ទោះជាយ៉ាងនេះក្តី និរន្តភាពនៃគំរូនេះនៅតែជាបញ្ហាប្រឈមដោយសារតែថវិកា PB និងSIG មិនមានគ្រប់គ្រាន់សម្រាប់រក្សាស្តង់ដារដែលគម្រោងផ្តល់ឲ្យ ក៏វាក៏មិនមែនជាប្រភពប្រាក់ចំណូលដែលផ្តល់ឲ្យបានទៀងទាត់ និងមាន



**តម្រូវការឪពុកម្តាយច្រើនជាងការរំពឹងទុក** មាតាបិតាសិស្សបំពេញបែបបទចុះឈ្មោះនៅសាលាអនុវត្តដែលពិសោធន៍អភិបាលកិច្ច និងទម្រង់នៃការបង់ថ្លៃសិក្សា។

ភាពបត់បែនគ្រប់គ្រាន់នោះដែរ។

នៅក្នុងឆ្នាំ២០១៤ អង្គការខេបបានចាប់ផ្តើមការពិសោធន៍ដ៏ធំមួយនៅក្នុងសាលាអនុវត្តនៅក្នុងក្រុងកំពង់ចាម ដើម្បីទ្រទ្រង់គំរូនេះដោយមានការគាំទ្រពីឪពុកម្តាយសិស្ស ដោយដាក់ចេញនូវការប្តេជ្ញាចិត្តខ្ពស់ក្នុងការលប់បំបាត់អំពើពុករលួយដែលបានរីករាលដាលក្នុងប្រព័ន្ធអប់រំ។ ការសន្យាទាំងនេះផ្សារភ្ជាប់ជាមួយស្តង់ដារអប់រំខ្ពស់ដែលបានរៀបចំជាមុនធ្វើជាបុរេលក្ខខណ្ឌចំពោះការបង់ថ្លៃសិក្សាដោយស្ម័គ្រចិត្ត សម្រាប់ឪពុកម្តាយដែលមានជីវភាពថ្នាក់កណ្តាល។ ការចរចាស្រដៀងគ្នានេះនឹងត្រូវយកទៅអនុវត្តសម្រាប់សាលាពីរទៀតរបស់គម្រោងដោយរង់ចាំលទ្ធផលនៃការសាកល្បងនៅក្នុងសាលាអនុវត្តជាមុនសិន។

**ការប្តេជ្ញាចិត្តដើម្បីឲ្យមានអភិបាលកិច្ចល្អ គឺជាបុរេលក្ខខណ្ឌនៃការចាប់ផ្តើមការបង់ថ្លៃការសិក្សាដោយស្ម័គ្រចិត្ត**

នៅដើមខែកញ្ញាឆ្នាំ២០១៤ សាលាអនុវត្តបានធ្វើប័ណ្ណផ្សព្វផ្សាយមួយដោយសន្យាជាមួយឪពុកម្តាយថានឹងផ្តល់សេវាកម្មគុណភាពអប់រំខ្ពស់សម្រាប់រចនាសម្ព័ន្ធអភិបាលកិច្ចថ្មីនេះ (មើលខាងក្រោម)។ ប័ណ្ណផ្សព្វផ្សាយនេះត្រូវបានជ្រួតជ្រាបយ៉ាងទូលំទូលាយដល់សហគមន៍ទាំងមូល ដោយបានបង្ហាញដល់ឪពុកម្តាយសិស្សដែលនាំកូនមកចុះឈ្មោះ និងបានផ្សព្វផ្សាយតាមរយៈបណ្តាញផ្សព្វផ្សាយសង្គមរបស់គម្រោងថែមទៀតផង។ ជាផ្នែកមួយនៃដំណើរការចរចារជាមួយសហគមន៍ សាលាបានសន្យាដូចខាងក្រោម៖

1) គ្រូបង្រៀនយល់ព្រមឲ្យសាលារៀនលប់បំបាត់រាល់ទម្រង់នៃការបង់ថ្លៃរៀនគួរ[5](ជំនួសមកវិញនូវការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម និងឱកាសទទួលបានប្រាក់លើកទឹកចិត្តតាមការបំពេញភារកិច្ច)។
2) សកម្មភាពនៃលក់នំឲ្យសិស្ស(ការបង្ខំ)នៅក្នុងថ្នាក់រៀនត្រូវបានលប់បំបាត់
3) សកម្មភាពយកថ្លៃក្រដាស់ប្រឡងក៏ត្រូវលប់បំបាត់
4) សិស្សអាចប្រើប្រាស់បរិក្ខាមានគុណភាពខ្ពស់រួមទាំងបន្ទប់វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ មណ្ឌលព័ត៌មានទទួលបានវិធីសាស្ត្របង្រៀនដោយបញ្ច្រាបបច្ចេកវិទ្យាព័ត៌មាន ICT និងសេវាកម្មអាហារដ្ឋានផងដែរ។
5) មាតាបិតានឹងទទួលបានព័ត៌មានស្តីពីសិស្សអវត្តដោយគ្មានមូលហេតុ (ដែលបច្ចុប្បន្នកំពុងអនុវត្តនៅតាមសាលារៀនឯកជន)
6) សាលានឹងរាយការណ៍ទៅក្រុមប្រឹក្សាភិបាល ដែមមានសមាសភាពមកពីមន្ទីរអប់រំ និងអង្គការខេប ព្រមទាំងផ្តល់របាយការណ៍ត្រីមាសស្តីពីការប្រើប្រាស់មូលនិធិ (ភាគច្រើនគឺការបន្ថែមប្រាក់ខែគ្រូ និងការផ្តល់ថវិកាលើកិច្ចការពិសេសសម្រាប់ក្លិបសិក្សា សេវាផ្តល់ប្រឹក្សាអាជីព ជាដើម។)

[5] Private tutoring that is mandatory for promotion

ប័ណ្ណផ្សព្វផ្សាយ និងខ្លឹមសារលម្អិតមានសង្ខេបដូចខាងក្រោម:



**What we provide. . .**

**Educational Facilities**

- ICT Lab for Students in Grades 4 to 10
- State of the art Science Education Lab
- Library & Media Center with access to Mobile Learning Devices for Grades 1 to 3
- Experimental Classrooms for Early Grade Literacy
- Playgrounds and Sports Facilities
- Student Canteen
- Art Room Facilities

**Teaching Methods and Programming**

At the Demonstration School, our teachers use the newest instructional methods to teach your children including Cooperative Learning, Project Method, and Constructivist Learning.

We also provide support for Subject Clubs in Science, Writing, History, Film and other Subjects

**Other Services:**

- Optional lessons in Chinese
- Career Counseling
- Fish & Frog Raising
- Mushroom Cultivation
- Hydroponic Gardening
- Field Trips
- Working with Australian youth



**Our Commitment to your Children . . .**

**We promise that . . .**

- We will not allow teachers to charge *rien kua* fees that are mandatory for passing
- We will not allow teachers to sell cakes and snacks in the classroom
- We will keep you informed of your child's learning and when they are absent from school
- We promise that we will treat all children equally and place the highest priority on their learning
- We will not charge for test papers during examinations
- We will not use corporal punishment to maintain discipline

**To maintain our educational standards, we ask assistance from parents as follows:**

- A voluntary user fee of $65/year ($32.50 per semester) to supplement the salaries of teachers and maintain the school and its facilities (for new students ONLY)
- Attend regular parent meetings where we report on school issues and how we use income from all sources.

**Our Commitment to Help the Poor**

The Demonstration School will admit about 140 new students in 2014-15. We will keep 50% of these places as free seats for parents who cannot afford to pay, pending a household visit to verify income.

***ប័ណ្ណផ្សព្វផ្សាយ និងការសន្យា****:* *សាលាអនុវត្តបានសន្យាជាសាធារណៈដល់សហគមន៍ស្ដីពគុណភាពនិង អភិបាលកិច្ច*

## ការណែនាំពីការបង់ថ្លៃការសិក្សាដោយស្ម័គ្រចិត្ត និងការចរចារដែលត្រូវធ្វើ:

ការសម្រេចដាក់ឲ្យអនុវត្តទម្រង់នៃការបង់ថ្លៃការសិក្សាមិនមែនធ្វើឡើងក្នុងកម្រិតទាបទេ និងតម្រូវឲ្យមានការពិភាក្សានៅថ្នាក់ខ្ពស់ជាមួយនឹងក្រសួង ដើម្បីទទួលបានការណែនាំពីវិធីដាក់ឲ្យអនុវត្តការបង់ថ្លៃនេះ ជាពិសេស ការចរចារជាមួយមាតាបិតាសិស្ស។ ដោយផ្អែកលើការពិភាក្សាទាំងនេះ ក្រសួងបានអនុញ្ញាតឲ្យខេបផ្តួចផ្តើមការពិភាក្សាជាមួយឪពុកម្តាយសិស្ស និងគ្រូបង្រៀនអំពីរចនាសម្ព័ន្ធអភិបាលកិច្ចថ្មីៗ និងលទ្ធភាពនៃការបង់ថ្លៃដោយស្ម័គ្រចិត្ត ធ្វើជាមធ្យោបាយមួយសម្រាប់រក្សាស្តង់ដារអប់រំខ្ពស់។ ប្រសិនបើឪពុកម្តាយឯកភាពចំពោះការបរិច្ចាកដោយស្ម័គ្រចិត្តនេះ និងប្រសិនបើការចរចារជាមួយគ្រូក៏សម្រេចបានការព្រមព្រៀងបញ្ឈប់សកម្មភាពយកថ្លៃសេវាក្រៅផ្លូវការ នោះខេបអាចបោះជំហានទៅមុខទៀតជាមួយនឹងផែនការចាប់ផ្តើមទម្រង់នៃការបង់ថ្លៃដោយស្ម័គ្រចិត្ត។

ស្របគ្នានេះភ្នាក់ងារបានចាប់ផ្តើមចរចារជាមួយឪពុកម្តាយ ដែលមានជីវភាពមធ្យមអំពីលទ្ធភាព និងឆន្ទៈក្នុងការជួយគាំទ្រដល់សាលារៀនតាមរយៈការបង់ថ្លៃសេវាដោយស្ម័គ្រចិត្ត ដែលជាមធ្យោបាយសម្រាប់ជំនួសថវិកាពីម្ចាស់ជំនួយដែលនឹងត្រូវបញ្ចប់នៅរយៈពេលពីរឆ្នាំខាងមុខនេះ។ ប្រព័ន្ធថ្មីនេះអនុវត្តតែចំពោះសិស្សថ្មីដែលបានចុះឈ្មោះចូលរៀននៅសាលាអនុវត្តប៉ុណ្ណោះ ដើម្បីសិស្សដែលបានចុះឈ្មោះរួចពីមុន (ភាគច្រើនជាសិស្សក្រីក្រ) គឺមិនមានប៉ះពាល់ទេ។ សម្រាប់សិស្សថ្មីចន្លោះពី៣០%ទៅ៥០%កន្លែងត្រូវបានបំរុងទុកសម្រាប់សិស្សក្រីក្រ និងសម្រាប់សិស្សទាំងឡាយណាដែលបានដាក់ពាក្យសុំមិនបង់ថ្លៃ(ដោយមានការវាយតម្លៃជីវភាព

គ្រួសារ)។ គម្រោងមានការប្រុងប្រយ័ត្នណាស់មុននឹងដាក់ឲ្យអនុវត្តទម្រង់នៃការបង់ថ្លៃសេវាថ្មីនេះ ហើយក៏បានពិភាក្សាបញ្ហានេះជាមួយនឹងមន្ទីរអប់រំរួចជាមុន ក្នុងកិច្ចប្រជុំប្រឹក្សាភិបាលកាលពីខែកញ្ញាឆ្នាំ២០១៤កន្លងទៅ។ បន្ទាប់ពីការពិភាក្សាទាំងអស់នេះ និងក្រោយពីមានការទទួលស្គាល់ពីក្រសួងដូចបានបញ្ជាក់ខាងលើ ផែនការពិសេសតែមួយគត់ និងមិនធ្លាប់មានពីមុនមកស្តីពីវិភាគទានហិរញ្ញវត្ថុដោយស្ម័គ្រចិត្តពីឪពុកម្តាយសិស្សដែលមានជីវភាពមធ្យមទីបំផុតត្រូវបានផ្សព្វផ្សាយជាសាធារណៈ កាលពីថ្ងៃទី១៥ ខែកញ្ញាឆ្នាំ២០១៤ កន្លងទៅ សម្រាប់សិស្សថ្មីចូលរៀននៅសាលាអនុវត្ត។ ថ្លៃសេវាត្រូវបានកំណត់សមរម្យគឺ ៦៥ដុល្លាក្នុងមួយឆ្នាំ ឬ៣២.៥០ដុល្លាក្នុងមួយឆមាស។ នេះបើប្រៀបធៀបជាមួយនឹងសាលាឯកជនក្នុងមូលដ្ឋានគឺ៤០០ដុល្លាក្នុងមួយឆ្នាំ ហើយស្រដៀងគ្នានេះដែរ ការបង់ថ្លៃក្រៅផ្លូវការយ៉ាងខ្ពស់នៅតាមសាលារៀនរដ្ឋផ្សេងៗទៀតនៅក្នុងតំបន់។ ជំនួសឲ្យការបង់ថ្លៃការសិក្សាបែបនេះ សាលារៀនបានសន្យាថានឹងលប់បំបាត់ចោលនូវរាល់ប្រព័ន្ធមិនផ្លូវការ និងខុសច្បាប់នានាដែលជាមេរោគរ៉ាំរ៉ៃនៅតាមសាលារដ្ឋនានា។ ប័ណ្ណផ្សព្វផ្សាយដូចដែលបានបង្ហាញខាងលើបានចែករំលែកទៅដល់ឪពុកម្តាយក្នុងកំឡុងពេលពិភាក្សាអំពីការបង់ថ្លៃការសិក្សាដោយស្ម័គ្រចិត្ត។

**ការអនុវត្តគោលការណ៍បង់ថ្លៃសិក្សាគឺសម្រាប់តែសិស្សចុះឈ្មោះចូលរៀនថ្មីប៉ុណ្ណោះ** ដោយសារតែសិស្សភាគច្រើនបានចុះឈ្មោះចូលរៀននៅសាលាអនុវត្តនៅឆ្នាំដំបូងៗជាសិស្សមកពីគ្រួសារក្រីក្រ សាលារៀននៅតែរក្សាលក្ខខ័ណ្ឌនៃចុះឈ្មោះសិក្សាដោយមិនបង់ថ្លៃដដែល ដោយជ្រើសរើសឲ្យមានប្រព័ន្ធបង់ថ្លៃដោយស្ម័គ្រចិត្តសម្រាប់សិស្សថ្មីប៉ុណ្ណោះ ដូចបានបញ្ជាក់ខាងដើម។ ក្រុមប្រឹក្សាភិបាលបានពិនិត្យឡើងវិញពីសមត្ថភាពរូបវន្តសាលាអនុវត្តទាំងបឋម និងមធ្យមសិក្សាដើម្បីកំណត់ចំនួនសិស្សថ្មីជាមួយនឹងការគ្រប់គ្រងសាលាផងដែរ។ នេះរួមទាំងសិស្សថ្មីសរុបចំនួន៥០នាក់នៅបឋមសិក្សា និង៩០នាក់នៅមធ្យមសិក្សា។ ដូចនេះសាលារៀនអាចទទួលសិស្សថ្មីបានចំនួន១៤០នាក់ បន្ថែមទៀត ក្នុងនោះចំនួន៧០កន្លែងនឹងត្រូវរក្សាទុកសម្រាប់សិស្សក្រីក្រដែលគ្រួសារមិនមានលទ្ធភាពបង់ថ្លៃការសិក្សា។ ជាទូទៅសាលារៀននៅតែរក្សាផលធៀបសិស្ស និងគ្រូចំនួន 36:1។

ទោះជាយ៉ាងនេះក្តី ក្នុងរយៈពេលមិនដល់ពីរសប្តាហ៍ផងបន្ទាប់ពីចាប់ផ្តើមដំណើរការចុះឈ្មោះចូលរៀន សិស្សថ្មីចំនួន១៦១នាក់បានដាក់ពាក្យចុះឈ្មោះចូលរៀន (៨៦នាក់នៅមធ្យមសិក្សា និង៧៥នាក់នៅបឋមសិក្សា) ពេញលើសសមត្ថភាពរបស់សាលារៀនបច្ចុប្បន្ន និងតម្រូវឲ្យមានភាពបត់បែនខ្លះៗចំពោះផលធៀបរវាងសិស្ស និងគ្រូដែលបានកំណត់។ ការមកចុះឈ្មោះសិស្សចូលរៀននៅសាលាអនុវត្ត យ៉ាងឆាប់រហ័សបែបនេះ សរបញ្ជាក់ឲ្យឃើញពីការផ្លាស់ប្តូរទស្សនៈរបស់សហគមន៍ក្នុងមូលដ្ឋានមកលើសាលារៀន ដែលពីមុនធ្លាប់គេចចេញពីសាលារៀននេះ។ ប្រការគួរឲ្យភ្ញាក់ផ្អើលជាងនេះទៅទៀត ឪពុកម្តាយសិស្សចំនួន១១២នាក់បានស្ម័គ្រចិត្តចុះឈ្មោះយល់ព្រមផ្តល់វិភាគទានថវិកាចំនួន៦៥ដុល្លា/ឆ្នាំ។ នេះមានន័យថាស្ទើរតែ៧០%នៃសិស្សថ្មីគឺចេញមកពីគ្រួសារកម្រិតមធ្យម គឺច្រើនជាងការរំពឹងទុកពីដំបូង។ ឪពុកម្តាយដែលមានឆន្ទៈ និងអាចចូលរួមបរិច្ចាកដោយស្ម័គ្រចិត្តត្រូវបានស្នើឲ្យចុះហត្ថលេខាលើសេចក្តីបញ្ជាក់ ដែលបានបង្ហាញពីឆន្ទៈក្នុងការបង់ថ្លៃការសិក្សានេះ ការបង់នេះ

ធ្វើឡើងដោយគ្មានការបង្ខិតបង្ខំណាមួយឡើយ។ សម្រាប់ឪពុកម្តាយដែលស្នើសុំមិនបង់ប្រាក់ត្រូវប្រើទម្រង់អង្កេតប្រាក់ចំណូលគ្រួសារធ្វើឡើងដោយគណៈកម្មការទ្រទ្រង់សាលា ដើម្បីបញ្ជាក់ពីកង្វះលទ្ធភាពក្នុងការផ្តល់វិភាគទានបែបនេះដល់សាលា។ ពុំមានសិស្សណាម្នាក់ត្រូវបានបដិសេធមិនឲ្យចុះឈ្មោះចូលរៀនក្នុងសាលានោះទេ ហើយការអនុញ្ញាតទទួលគឺផ្អែកលើមូលដ្ឋានមកដល់មុនទទួលបានសេវាមុន។

**លទ្ធផលបឋមៈ** ចេញពីអ្វីៗដែលបានពណ៌នាខាងលើ ឪពុកម្តាយដែលមានជីវភាពមធ្យមបានសំដែងឲ្យឃើញនូវចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះគោលនយោបាយថ្មីរបស់សាលាអនុវត្តក្នុងការលុបបំបាត់ប្រព័ន្ធថ្លៃសេវាក្រៅផ្លូវការដោយអនុវត្តការបង់ថ្លៃសិក្សាដោយស្ម័គ្រចិត្ត និងមានតម្លាភាព។ លើសពីនេះទៀតប្រហែលជា១០%នៃសិស្សចុះឈ្មោះចូលរៀនថ្មីគឺជាសិស្សដែលពីមុនរៀននៅសាលារៀនឯកជនជិតៗនេះ ហេតុដូចនេះវាបានជួយឲ្យសាលារដ្ឋឲ្យមានលទ្ធភាពប្រកួតប្រជែងជាមួយសាលារៀនឯកជន ដែលបានស្រូបយកសិស្សពីសាលារៀនរដ្ឋកន្លងមក។

មាតាបិតាសិស្សបានសំដែងឲ្យឃើញចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការឲ្យកូនចុះឈ្មោះចូលរៀនសាលារៀនដែលមិនត្រឹមតែផ្តល់ការអប់រំមានគុណភាពខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានរចនាសម្ព័ន្ធអភិបាលកិច្ចថ្មីដែលមានភាពកាន់តែងសមស្រប តម្លាភាព និងសមធម៌។ ទាំងអង្គការខេប ក៏ដូចជាមន្ទីរអប់រំមិនបានទទួលពាក្យបណ្តឹង ឬការតវាណាមួយអំពីប្រព័ន្ធថ្មីនេះទេ ប្រការនេះវាបានផ្តល់សុពលភាពចំពោះការសម្រេចរបស់ក្រសួងអប់រំ និងអង្គការខេប ដែលបានប្រឈមនឹងហានិភ័យក្នុងការបង្ហាញប្រព័ន្ធនៃការអភិបាលកិច្ចថ្មីដែលបានបង្កើតឡើងនេះដើម្បីលុបបំបាត់អំពើពុករលួយដ៏រ៉ាំរ៉ៃនៅក្នុងប្រព័ន្ធអប់រំនៅសាលារៀន។ នៅក្រោមប្រព័ន្ធនេះ សិស្សក្រីក្រអាចទទួលបាននូវប្រព័ន្ធអប់រំមានគុណភាពខ្ពស់ពីសាលារដ្ឋ ដោយមិនចាំបាច់បង់ថ្លៃពិតប្រាកដ (មិនដូចជាប្រព័ន្ធអប់រំបច្ចុប្បន្នដែលជាផ្លូវការមិនមានការបង់ថ្លៃទេ ប៉ុន្តែគ្រប់គ្នាត្រូវបង់ ទោះបីជាអ្នកមាន ឬអ្នកក្រ)។

## 3.3 ការប៉ាន់ស្មានតម្លៃរបស់គំរូអប់រំថ្មី និងនិរន្តរភាពនាពេលអនាគត

អង្គការខេបបានចំណាយអស់រយៈពេលប្រហែលជាបីឆ្នាំកន្លះ ដើម្បីបង្កើតគំរូអប់រំមានគុណភាពខ្ពស់ដែលទទួលបានការគោរពជាទូទៅយ៉ាងល្អពីសហគមន៍ក្នុងមូលដ្ឋានក្នុងក្រុងខេត្តកំពង់ចាមនេះ។ សម្រាប់រយៈពេល២ឆ្នាំចុងក្រោយនេះ គម្រោងផ្តោតសំខាន់លើកិច្ចប្រឹងប្រែងធានានិរន្តរភាពគំរូនេះ ព្រោះការគាំទ្រផ្លូវពីប្រព័ន្ធអប់រំ(ភាគច្រើនជាថវិកា *PB* និង *SIG*) បង្ហាញយ៉ាងច្បាស់ថាមិនគ្រប់គ្រាន់សម្រាប់អនុវត្តគំរូនេះបាន ហើយការគាំទ្រពីម្ចាស់ជំនួយនឹងត្រូវបញ្ចប់នៅឆ្នាំ២០១៦ខាងមុខនេះ។ នេះមានន័យថា ការរៀបចំឲ្យមានកិច្ចចរចារ ស្រដៀងគ្នាជាមួយឪពុកម្តាយសិស្ស និងគ្រូបង្រៀននៅសាលាផ្សេងទៀតត្រូវផ្អែកលើបទពិសោធន៍នៅសាលាអនុវត្ត។

ការវិភាគពីចរន្តចំណាយបច្ចុប្បន្នក្នុងការផ្តល់សេវាអប់រំមានគុណភាពខ្ពស់ នៅសាលាអនុវត្តនេះតាមការប៉ាន់ស្មានត្រូវការចំណាយប្រមាណ២៥,០០០ដុល្លាក្នុងមួយឆ្នាំសម្រាប់សាលារៀន ដែលមានគ្រូចំនួន២៣នាក់

កំពុងបម្រើការប្រកបដោយប្រសិទ្ធភាពខ្ពស់។ ថវិកានេះរួមបញ្ចូលទាំងការចំណាយលើការគាំទ្រដល់គ្រូបង្រៀនសាលាបឋមសិក្សាផងដែរ ដែលបច្ចុប្បន្នបង្រៀនប្រាំមួយម៉ោងក្នុងមួយថ្ងៃតាមស្តង់ដារអន្តរជាតិ។ នេះក៏រួមបញ្ចូលទាំងការចំណាយសម្រាប់ការបង់ប្រាក់ឧបត្ថម្ភបន្ថែមដល់គ្រូបង្រៀន និងប្រាក់បន្ថែមសម្រាប់នាយកសាលា ២០០ដុល្លាក្នុងមួយខែ ប្រាក់សម្រាប់សន្តិសុខ ការជួសជុល/ថែរក្សា និងថវិកាអំណោយសាលាចំនួន៣០០០ ដុល្លាសម្រាប់ធ្វើសកម្មភាពផ្សេងៗសំដៅលើកកម្ពស់គុណភាពអប់រំទៀតផង។ ការចំណាយនេះមានបង្ហាញលម្អិតក្នុងតារាងទី១ខាងក្រោមនេះ។

**តារាងទី១: ការចំណាយលម្អិត និងប្រភពចំណូលសំខាន់ៗនៅសាលាអនុវត្ត**

| ចំណាយសំខាន់ៗប្រចាំឆ្នាំ | ភាគរយលម្អិត | | ប្រភពប្រាក់ចំណូល | ភាគរយលម្អិត |
|---|---|---|---|---|
| ប្រាក់ឧបត្ថម្ភគ្រូបង្រៀន | 73% | | វិភាគទានឪពុកម្តាយសិស្ស | 31% |
| អំណោយសាលារៀន | 10% | | ចំណូលពីអាហារដ្ឋាន | 6% |
| សន្តិសុខ | 7% | | ចំណូលផ្សេងៗក្នុងសាលា | 3% |
| ការគ្រប់គ្រង | 9% | | អំណោយស្ថាប័នឯកជន | 8% |
| ការថែទាំ | 1% | | ថវិកា *Endowment Fund* | 4% |
| សរុប | **100%** | | ប្រភពចំណូលពីគម្រោង/ថវិកាផ្ទៃក្នុងរបស់ខេប | 48% |
| | | | សរុប | **100%** |

ជាការច្បាស់ហើយថា ខ្ទង់ចំណាយដ៏ច្រើនជាងគេគឺសម្រាប់ឧបត្ថម្ភគ្រូ(73%) ដែលជាមធ្យោបាយទប់ស្កាត់គ្រូមិនឲ្យយកថ្លៃសេវាក្រៅផ្លូវការផ្សេងៗពីសិស្ស និងដើម្បីបង្កើនម៉ោងបង្រៀនពី៤ម៉ោងទៅ៦ម៉ោងសម្រាប់គ្រូបង្រៀនសិស្សនៅបឋមសិក្សា។ រហូតមកដល់ពេលនេះការចំណាយរបស់សាលាគំរូថ្មីនេះនៅតែលើសពីប្រាក់ចំណូលពីប្រព័ន្ធបង់ថ្លៃសេវាដោយស្ម័គ្រចិត្ត និងប្រពភចំណូលផ្សេងទៀតដោយមានឱនភាព ដែលបច្ចុប្បន្ននេះត្រូវបំពេញដោយធនធានផ្ទៃក្នុងរបស់ខេប និងពីគម្រោង*BSI*។ កិច្ចខិតខំប្រឹងប្រែងដើម្បីទ្រទ្រង់គំរូនេះទទួលបានជោគជ័យរហូតមកដល់ពេលនេះដោយអាចរ៉ាប់រងបាន 52% នៃចំណាយសរុប។ វិភាគទានឪពុកម្តាយគឺជាផ្នែកដ៏ធំបំផុតនៃប្រាក់ចំណូល(31%) រួមជាមួយនឹងវិធានការណ៍ផ្សេងៗទៀតដូចជាថវិកា*Endowment Fund*[6]ដែល

[6] Apple donated $ 20 000 to KAPE to establish and Endowment that will be put into low risk investments that should generate a return on base capital of 5-10% per annum.

ខេបបានបង្កើតឡើងនាពេលថ្មីៗនេះដោយទទួលបានជំនួយពីក្រុមហ៊ុន *Apple Corporation*។

ទោះជាយ៉ាងណា ខេបរំពឹងថាដោយមានសិស្សចុះឈ្មោះថ្មីបន្ថែម នឹងបង្កើនប្រាក់ចំណូល និងសង្ឃឹមថានឹងទទួលបានការឧបត្ថម្ភបំពេញបន្ថែមពីមូលនិធិសមធម៌សង្គម (*Social Equity Fund*) ដែលក្រសួងកំពុងធ្វើការពិចារណា ហើយទាំងអស់នេះសាលារៀនធានានិរន្តភាពគំរូអប់រំដែលមានគុណភាពខ្ពស់សម្រាប់អ្នកក្រីក្របំផុតទទួលបាននូវការអប់រំដោយមិនបង់ថ្លៃពីប្រព័ន្ធអប់រំរដ្ឋ។ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡាបានផ្តល់យោបល់ថាមូលនិធិសមធម៌សង្គមនឹងផ្តល់ដល់សាលារៀនណា ដែលអាចលុបបំបាត់ចោលប្រព័ន្ធយកថ្លៃសេវាក្រៅផ្លូវការដែលមានផលប៉ះពាល់អាក្រក់យ៉ាងធ្ងន់ធ្ងរដល់សិស្សក្រីក្រ និងជាសាលាដែលបានធ្វើឲ្យមានភាពប្រសើរឡើងលេចធ្លោផ្នែកគុណភាពអប់រំ។ ក្រុមការងារកំពុងត្រូវបានរៀបចំឡើង ដើម្បីកំណត់នូវលក្ខណៈនៃក្របខ័ណ្ឌបែបនេះ ដូចបានកត់សម្គាល់ខាងដើម។

## 4. បទពិសោធន៍ស្តីពីការអនុវត្តគម្រោងBSI

ដោយលទ្ធផលជោគជ័យរបស់គម្រោងសាលារៀនដៃគូ(BSI) ក្រសួងអប់រំយុវជននិងកីឡាក៏ព្រមទាំងដៃគូអភិវឌ្ឍមួយចំនួនមានចំណាប់អារម្មណ៍ក្នុងការចម្លង និងពង្រីកគំរូនេះឲ្យបានទូលំទូលាយថែមទៀត។ ទោះជាយ៉ាងនេះក្តី មុនពេលចាប់ផ្តើមការងារនេះ មានមេរៀនបទពិសោធសំខាន់ៗជាច្រើន ដែលអាចជួយឲ្យជៀសផុតពីកំហុសធំៗ និងបង្កើននូវប្រសិទ្ធភាព។ មេរៀនសំខាន់ៗមួយចំនួនស្តីពីគំរូនេះមានក្នុងសេចក្តីសង្ខេបខាងក្រោមៈ

1. ការជ្រើសរើសសាលាៈ BSI បានជ្រើសរើសធ្វើការនៅទីតាំងបី ដែលរួមមានសាលារៀនមានស្រាប់ចំនួនពីរ និងសាលារៀនហៀបនឹងបិទទ្វារមួយ ដែលត្រូវរៀបចំឲ្យដំណើរការឡើងវិញ(ធ្វើជាសាលាថ្មីទាំងស្រុង)។ មានដែនកំណត់ច្រើនក្នុងការធ្វើការងារជាមួយសាលាដែលមានពីមុនស្រាប់ ពីព្រោះតែមិនមានភាពបត់បែនច្រើនក្នុងផ្លាស់ប្តូរគ្រូបង្រៀន និងនាយកសាលា។ លើសនេះទៀត ការធ្វើការងារជាមួយគ្រូបង្រៀនដែលមានស្រាប់ ធានាថានឹងមានភាពខុសគ្នាច្រើនទាំងក្នុងការលើកទឹកចិត្ត និងកម្រិតសមត្ថភាព ដែលបង្ករជាបញ្ហាសម្រាប់ការអនុវត្តកម្មវិធីផ្តល់ប្រាក់លើកទឹកចិត្តបន្ថែម។ ដូច្នេះសាលារៀនដែលមានស្រាប់មានឧបសគ្គច្រើនពាក់ព័ន្ធទៅនឹងអ្វីៗដែលយើងអាចសម្រេចនៅក្នុងសាលាថ្មី ឬសាលាជិតដួល ឬបិទទ្វារដែលផ្តល់នូវភាពបត់បែនច្រើន។ ដូចជាករណីBSI លទ្ធផលដែលទទួលបានជោគជ័យដ៏អស្ចារ្យនេះជាភស្តុតាងច្បាស់គឺសាលាអនុវត្ត ដែលសឹងតែជាសាលាថ្មីមួយ ចំពោះសាលាមានស្រាប់មួយដែលមាននាយកដ៏រឹងមាំ និងគ្រូខ្លាំងៗជាច្រើនបែរជាលទ្ធផលបានជោគជ័យកម្រិតមធ្យម ខណៈសាលាមានស្រាប់ទី៣ដែលមានអ្នកដឹកនាំទន់ខ្សោយ និងគ្រូមានការបែកបាក់គ្នាជាក្រុមៗ គឺបានជោគជ័យកម្រិតទាបជាងគេក្នុងចំណោមសាលាបី។ ដូចនេះ ការបង្កើតឲ្យមានសាលាគំរូដូចដែលបានស្នើឡើងនេះនៅក្នុងសាលារៀនដែលមានស្រាប់នឹងជួបប្រទះការលំបាកច្រើនបំផុត។

2. ទីតាំងប្រជាសាស្ត្រ: ការធានានូវនិរន្តរភាពរបស់សាលាគំរូBSIតម្រូវឲ្យមានការគាំទ្រពីឪពុកម្ដាយដែលមានជីវភាពកម្រិតមធ្យមតាមរយៈប្រព័ន្ធបង់វិភាគទានដោយស្ម័គ្រចិត្ត។ ដូចនេះ សក្ដានុពលដ៏ល្អបំផុតសម្រាប់និរន្តភាពរបស់គំរូនេះ តម្រូវឲ្យមានការកំណត់ប្រជាសាស្ត្រក្នុងតំបន់ទីប្រជុំជន ឬពាក់កណ្ដាលប្រជុំជនដែលជាប់នឹងសហគមន៍ជនបទ។ ការកណត់យកតំបន់ជនបទទាំងស្រុងគឺមានន័យថាមិនអាចធានានិរន្តរភាពដោយងាយស្រួលបានទតាមរយៈការគាំទ្រពីមូលដ្ឋាននោះ។

3. ទំហំសាលារៀន: ឱកាសខ្ពស់បំផុតសម្រាប់ចម្លងគំរូនេះឲ្យទទួលបានជោគជ័យគួរតែអនុវត្តនៅតាមសាលាតូចៗទៅមធ្យម ដែលមានគ្រូត្រឹមតែ២៥នាក់ឬតិចជាងនេះ។ សាលារៀនមានទំហំតូចធ្វើឲ្យកាន់តែមានភាពងាយស្រួលអនុវត្តកម្មវិធីបានស៊ីជម្រៅ កាត់បន្ថយតម្រូវការតាមដាន និងធ្វើឲ្យទំហំនៃការវិនិយោគកាន់តែអាចគ្រប់គ្រងបាន។ នៅពេលគេធ្វើការក្នុងសាលាមានគ្រូច្រើនជាង៣០នាក់ ការត្រួតពិនិត្យទាមទារកម្លាំងពលកម្មច្រើន ចំណែកទំហំវិនិយោគក៏ខ្ពស់ ជាពិសេសការចំណាយលើប្រាក់ឧបត្ថម្ភគ្រូ។

*4.* ការគាំទ្រពីមូលដ្ឋាន: ខេបទទួលបានការគាំទ្រខ្លាំងពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម ដែលបានផ្ដល់ការចូលរួមយ៉ាងសកម្មតាមរយៈក្រុមប្រឹក្សាភិបាល។ ប្រការនេះបង្ករលក្ខណៈអំណោយផលក្នុងធ្វើលំហាត់យន្តកាគណនេយ្យភាពឲ្យមានប្រសិទ្ធិភាព ដែលនាំឲ្យមានតម្រូវការផ្លាស់ប្ដូរនានាក្នុងសាលារៀនគោលដៅជាពិសេសពាក់ព័ន្ធទៅនឹងការជ្រើសរើសនាយកសាលា និងគ្រូបង្រៀនថ្មីៗ។ ជាការពិត វត្តមានការិយាល័យបុគ្គលិកក្នុងក្រុមប្រឹក្សាភិបាលជាការសំខាន់ណាស់ ព្រោះការចូលរួមការិយាល័យនេះមានសារៈសំខាន់ក្នុងការធ្វើការសម្រេចចាំបាច់នានាពាក់ព័ន្ធនឹងការតែងតាំងគ្រូបង្រៀន។

5. ការបង្កើតស្ដង់ដារអប់រំខ្ពស់គឺជាជំហានដំបូង: ការស្វះស្វែងរកការគាំទ្រពីក្រុមគ្រួសារដែលមានជីវភាពមធ្យមមានការលំបាកសម្រាប់គម្រោងសាលារៀនដៃគូនៅក្នុងដំណាក់កាលដំបូង ជាពិសេសប្រសិនបើសាលាដែលគម្រោងកំពុងជួយគាំទ្រជាសាលាដែលជិតដួលរលំ ឬជាសាលាថ្មីស្រឡាង។ ដូចនេះ កិច្ចខិតខំប្រឹងប្រែងដំបូងៗ ចាំបាច់ត្រូវផ្ដោតការយកចិត្តទុកដាក់លើការបង្កើតឲ្យបាននូវគុណភាព "ពេញលេញ" នៅដំណាក់កាលដំបូងនៃការអនុវត្តនៅក្នុងសាលា។ នៅពេលណាដែលសម្រេចលទ្ធផលហើយ វាកាន់តែងាយស្រួលក្នុងការសម្រេចបាននូវការផ្ដល់សេចក្ដីទុកចិត្ត និងទីបំផុតទទួលបានការគាំទ្រហិរញ្ញវត្ថុពីគ្រួសារក្នុងមូលដ្ឋានដែលមានលទ្ធភាព ដោយហេតុនេះវាជាការសម្រេចបាននិរន្តភាពក្នុងកម្រិតមួយចំនួន។

6. អភិបាលកិច្ចគឺជាកត្តាគន្លឹះ៖ លក្ខណៈពិសេសរបស់គម្រោងសាលារៀនដៃគូដែលធានាបាននូវភាពជោគជ័យគឺមិនមែនដោយសារការវិនិយោគយ៉ាងច្រើនទៅលើបរិក្ខា ការបំប៉ន ឬក៏ហេដ្ឋារចនាសម្ព័ន្ធនោះទេ បើទោះជាការវិនិយោគទាំងអស់នេះមានសារៈសំខាន់ក៏ដោយ។ គម្រោងផ្សេងៗទៀតក៏បានធ្វើការវិនិយោគផ្នែកនេះដែរ ដោយទទួលបានជោគជ័យតិចតួច។ ប្រការកាន់តែប្រសើរជាងការវិនិយោគខាងលើ គឺសមាសភាគគន្លឹះក្នុងការរៀបចំគម្រោងពាក់ព័ន្ធទៅនឹងកិច្ចប្រឹងប្រែងផ្លាស់ប្ដូរវប្បធម៌គណនេយ្យភាពកំសោយនៅក្នុងសាលារដ្ឋ។

នេះទាមទារវិធានការជាច្រើន រួមទាំងការបង្កើតក្រុមប្រឹក្សាភិបាល ដែលផ្សារភ្ជាប់ការផ្តល់ថវិកាលើកទឹកចិត្តគ្រូបង្រៀនជាមួយការបំពេញភារកិច្ច ការស្នើឲ្យនាយកសាលា និងគ្រូបង្រៀនចុះកិច្ចសន្យា ការផ្សព្វផ្សាយការសន្យារបស់សាលារៀនក្នុងការកែលម្អអភិបាលកិច្ចតាមរយៈប័ណ្ណផ្សព្វផ្សាយចែកជូនឪពុកម្តាយ និងវិធានការផ្សេងៗទៀត។ បើគ្មានវិធានការទាំងអស់នេះទេ ការវិនិយោគលើគុណភាពអប់រំមិនអាចយកទៅអនុវត្តបានជោគជ័យដូចរយៈកាលកន្លងមកនេះទេ។

7. កាលមើលឃើញពីគ្រោះថ្នាក់នៃផ្តល់ប្រាក់លើកទឹកចិត្តផ្អែកលើការបំពេញភារកិច្ច៖ គម្រោងBSIបានបង្កើតបទពិសោធន៍ដ៏មានសារប្រយោជន៍ជាច្រើនស្តីពីការប្រើប្រាស់ថវិកាលើកទឹកចិត្តតាមការបំពេញភារកិច្ច។ បើមិនបានគ្រប់គ្រងឲ្យបានត្រឹមត្រូវល្អទេ PbP អាចជាកម្លាំងធ្វើឲ្យបាក់ទឹកចិត្តនៅក្នុងសាលារៀនទៅវិញ ដែលនាំទៅដល់អ្វីមួយផ្ទុយទៅនឹងការគ្រោងទុក។ វាក៏អាចនាំឲ្យមានការច្រណែន និងបែកបាក់គ្នាក្នុងចំណោមគ្រូបង្រៀន។ BSI បានចងក្រងឯកសារសម្រាប់កសាងសមត្ថភាពដ៏មានសារសំខាន់មួយ ដែលពិភាក្សាពីរបៀបអនុវត្តប្រព័ន្ធ PbP ឲ្យមានប្រសិទ្ធភាព។ ឯកសារនេះផ្តោតលើគោលការណ៍សំខាន់ៗបី ដែលហៅថា ការបែងចែក PbP ត្រូវតែយុត្តិធម៌ មានតម្លាភាព និង តាមគោលការណ៍ច្បាប់។ គ្រូបង្រៀនទាំងអស់ត្រូវដឹងលក្ខខណ្ឌនានារបស់ថវិកាលើកទឹកចិត្តតាមភារកិច្ច PbP ត្រូវយកទៅអនុវត្ត ហើយកិច្ចការណាខ្លះដែលអាចទទួលបានថវិកាលើកទឹកចិត្តនេះ នាយកសាលារៀនត្រូវធានាថា ការសម្រេចបែងចែកថវិកា PbP មានយុត្តិធម៌ និងមិនលម្អៀង ហើយនាយកសាលាត្រូវធានាថែមទៀតថា ការផ្តល់ថវិកានេះមិនអាចកើតឡើងបានទេ ពេលដែលគ្រូមិនបានអនុវត្តកិច្ចការដែលគាត់បានព្រមព្រៀងធ្វើ។ នាយកសាលាភាគច្រើនចង់បានច្រកមួយដែលមានការជំទាស់តិចតួចបំផុត ដើម្បីជៀសវាងជម្លោះជាមួយគ្រូបង្រៀន ទោះជាយ៉ាងនេះក្តី នៅពេលគ្រប់គ្រងប្រព័ន្ធ PbP នាយកសាលាចាំបាច់ត្រូវប្រកាន់នូវយុត្តិធម៌ ប៉ុន្តែម៉ឺងម៉ាត់ក្នុងការគោរពលក្ខខណ្ឌនៃការផ្តល់ឬមិនផ្តល់ថវិកាលើកទឹកចិត្តតាមការបំពេញភារកិច្ចនេះ។

## 5. ការចាប់ផ្តើមមូលនិធិសមធម៌សង្គមដើម្បីពង្រីកស្តេរភាពសាលារៀនជំនាន់ថ្មី និងការចម្លងតាមគំរូនេះ

### 5.1 គោលធំៗនៃមូលនិធិសមធម៌សង្គម

បច្ចុប្បន្ននេះក្រសួងកំពុងតែធ្វើការពិចារណាពីការបង្កើតមូលនិធិសមធម៌ ដើម្បីជួយទ្រទ្រង់គំរូអប់រំដែលមានគុណភាពខ្ពស់ ដែលមានរចនាសម្ព័ន្ធអភិបាលកិច្ចថ្មីដូចគំរូដែលបានពណ៌នាខាងលើ។ទោះជាយ៉ាងនេះក្តី ការបង្កើត និងការគ្រប់គ្រងមូលនិធិជាតិបែបនេះ ទាមទារនូវការពិភាក្សាស៊ីជម្រៅបន្ថែមទៀត។ វាជាការចាំបាច់ខ្លាំងណាស់ ដែលមូលនិធិមួយបែបនេះត្រូវបានផ្តល់ទៅឲ្យសាលារៀនណាដែលអាចសម្រេចបាននូវស្តង់ដារអប់រំខ្ពស់តាមការព្រមព្រៀង។ ស្តង់ដារទាំងនេះអាចរួមបញ្ចូលទាំង"លក្ខណៈវិនិច្ឆ័យចាំបាច់" និង"លក្ខណៈវិនិច្ឆ័យជម្រើសបន្ថែម" ប៉ុន្តែមិនចាំបាច់តម្រូវឲ្យមានគ្រប់លក្ខណៈវិនិច្ឆ័យទាំងអស់នោះទេ។ ចំណុចស្នូលនៃស្តង់ដាទាំងនេះគឺរចនាសម្ព័ន្ធអភិបាលកិច្ចដែលធានាបាននូវការលុបចោលនូវប្រព័ន្ធបង់ថ្លៃសេវាក្រៅផ្លូវការ និងការអនុវត្តរដ្ឋបាលគ្មានតម្លាភាព។ នេះមានន័យថា គ្រូបង្រៀននៅតាមសាលាដែលដាក់ពាក្យសុំមូលនិធិត្រូវតែយល់ព្រមបញ្ឈប់សកម្មភាពឲ្យបង់ថ្លៃ "រៀនគួរ" ដែលជាប់ពាក់ព័ន្ធនឹងការសម្រេចឲ្យសិស្សឡើងថ្នាក់ក៏ដូចជាថ្លៃសេវាមិនផ្លូវការផ្សេងៗទៀតដែលបន្ទុចបង្អាក់ដល់ការទទួលបានសេវាដោយសមធម៌។ ជាថ្នូរមកវិញ សាលារៀននឹងផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមដល់គ្រូបង្រៀន អាចជាប្រាក់ថេរក៏បាន ឬប្រាក់តាមការបំពេញការងារ ឬ(យកល្អ) ជាបន្សំគ្នាទាំងពីរជម្រើសនេះ។ ចំណុចនេះគួរចាត់ទុកជាតម្រូវការគន្លឹះដើម្បីទទួលបានមូលនិធិ។ ការអនុវត្តជាប្រចាំនូវលក្ខណៈវិនិច្ឆ័យបែបនេះត្រូវត្រួតពិនិត្យឡើងវិញជាទៀងទាត់ និងការព្យួរទុកការទទួលបានមូលនិធិត្រូវតែអនុវត្តក្នុងករណីសាលាខកខានមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងនេះ។

សេចក្តីសង្ខេបសម្រាប់ផ្តល់ជាយោបល់ស្តីអំពីលក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបានមូលនិធិសមធម៌មានបង្ហាញជូនក្នុងតារាងលេខ១ខាងក្រោម។ គណៈកម្មការជាតិដូចជាគណៈកម្មការមួយដែលបានបង្កើតនាពេលថ្មីៗនេះដោយក្រសួងអប់រំ យុវជន និងកីឡា ដែលគេឲ្យឈ្មោះថាគណៈកម្មការជាតិវាយតម្លៃសាលារៀន នឹងពិនិត្យវាយតម្លៃសាលារៀនដែលបានដាក់ពាក្យសុំ ដើម្បីកំណត់ពីសិទ្ធិ ឬលក្ខណសម្បត្តិទទួលបានមូលនិធិសមធម៌របស់សាលានោះ។ គណៈកម្មការនេះនឹងប្រើវិនិច្ឆ័យសិទ្ធិពាក់ព័ន្ធទាំងផ្នែកអភិបាលកិច្ច និងគុណភាព ដូចដែលគណៈកម្មការសម្រាប់កិច្ចសហប្រតិបត្តិការនៅកម្ពុជា*(CCC)* តម្រូវឲ្យបំពេញតាមការអនុវត្តល្អ និងស្តង់ដារវិជ្ជាជីវៈ (GPP) សម្រាប់អង្គការក្រៅរដ្ឋាភិបាល តាមរយៈការផ្តល់វិញ្ញាបនប័ត្រ។ ជាការពិតណាស់គំរូ CCC បានផ្តល់ជាឧទាហរណ៍ល្អប្រសើរស្តីពីវិធីបង្កើតគណៈកម្មការជាតិមួយស្រដៀងគ្នានេះនៅក្នុងក្រសួង ដើម្បីពិនិត្យវាយតម្លៃសិទ្ធិទទួលបានមូលនិធិសមធម៌សង្គម។ ក្នុងន័យនេះCCC រក្សាគណៈកម្មការដាច់ដោយឡែកសម្រាប់ពិនិត្យលក្ខណៈវិនិច្ឆ័យ និងផ្តល់ជូនវិញ្ញាបនប័ត្រជាក់ស្តែង។ ក្រសួងក៏ប្រហែលជាមានបំណងពិចារណាអំពីការបង្កើតគណៈកម្មការដាច់ដោយឡែកពីគ្នា ដែលបញ្ជាក់ពីសិទ្ធិសម្រាប់ការដាក់ពាក្យសុំមូលនិធិសមធម៌ និងគណៈកម្មការដាច់

ដោយឡែកមួយដែលធ្វើការសម្រេចថា តើរង្វាន់គួរតែផ្តល់ឬមិនផ្តល់ ដើម្បីបង្ការនូវជម្លោះផលប្រយោជន៍ណាមួយដែលអាចកើតមានឡើង។ ជាការពិតណាស់ ឯករាជ្យភាពរបស់គណៈកម្មការទាំងពីរគឺជាតម្រូវការចាំបាច់ដើម្បីធានាបានថា រាល់ការសម្រេចគឺធ្វើឡើងដោយមិនលម្អៀង និងសមស្រប។

**ប្រអប់ទី១: ជំនួយបច្ចេកទេសចាំបាច់ពីដៃគូអភិវឌ្ឍដើម្បីបង្កើតមូលនិធិសមធម៌សង្គម**

- រៀបចំគោលដៅ និងនិតិវិធីប្រតិបត្តិការសម្រាប់គណៈកម្មការកំណត់ពីសិទ្ធិដែលទទួលបានមូលនិធិសមធម៌។
- ចងក្រងគោលដៅ និងនិតិវិធីប្រតិបត្តិការសម្រាប់គណៈកម្មការប្រគល់មូលនិធិសមធម៌សង្គម ។
- ចងក្រងនិយមន័យលក្ខណវិនិច្ឆ័យស្តង់ដារសម្រាប់សិទ្ធិទទួលបានពីមូលនិធីសមធម៌សង្គម និងវិធីវាស់វែងលក្ខណៈវិនិច្ឆ័យទាំងនេះ។
- ការវិនិយោគលើសម្ភារៈ ឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធដើម្បីគាំទ្រឲ្យមានភាពប្រសើរឡើងលើបរិស្ថានសិក្សា នៅសាលារៀនដែលឈរឈ្មោះ។
- ជំនួយបច្ចេកទេសសម្រាប់កែលម្អអភិបាលកិច្ចនិង បរិស្ថាននៃការបង្រៀន និងរៀន។
- ចងក្រងគោលការណ៍ណែនាំសម្រាប់ប្រើប្រាស់មូលនិធិសមធម៌សង្គម
- ការបង្កើតក្រុមប្រឹក្សាភិបាលថ្នាក់ខេត្តដែលមានសមាជិកយ៉ាងហោចណាស់១ទៅ២ មកពីអង្គការសង្គមស៊ីវិល ដែលមានម្នាក់ជាគណៈកម្មការទ្រទ្រង់សាលា ។
- រៀបចំគោលការណ៍ណែនាំពីប្រាក់ឧបត្ថម្ភបន្ថែមតាមការបំពេញភារកិច្ច

នៅពេលដែលសាលារៀនមួយសម្រេចបានដោយជោគជ័យ នូវលក្ខណៈវិនិច្ឆ័យសិទ្ធិសម្រាប់ទទួលបានមូលនិធិសមធម៌សង្គម(SEF) សាលានោះក៏ត្រូវទទួលបានការអនុញ្ញាតឲ្យចរចារជាមួយឪពុកម្តាយសិស្ស ដើម្បីចាប់ផ្តើមអនុវត្តការបង់ថ្លៃដោយស្ម័គ្រចិត្ត ស្រដៀងគ្នាទៅនឹងវិធីដែលសាលាអនុវត្ត ខេត្តកំពង់ចាមបានធ្វើកន្លងមក។ ទោះជាយ៉ាងនេះក្តី ការព្រមព្រៀងពីមាតាបិតាសិស្ស និងការទទួលស្គាល់ពីដៃគូសង្គមស៊ីវិលមានសារៈសំខាន់ ដើម្បីបញ្ជាក់ថាការបង់ថ្លៃដោយស្ម័គ្រចិត្តធ្វើឡើងដោយមានការព្រមព្រៀងពីមាតាបិតា ចំណែកសិស្សក្រីក្រក៏មិនត្រូវបានបដិសេធមិនឲ្យមកចុះឈ្មោះចូលរៀនដែរ។ ជាការពិតណាស់ ថ្លៃបង់សាលារបស់គ្រួសារក្រីក្រនឹងត្រូវដកចេញពីខ្ទង់មូលនិធិសមធម៌សង្គម។ ការផ្តល់ឲ្យបែបនេះនឹងដើរតួជាការលើកទឹកចិត្ត សម្រាប់ទាក់ទាញសិស្សក្រីក្រឲ្យចូលរៀនក្នុងសាលានេះទៀតផង ព្រោះថាកាលណាសិស្សក្រីក្រកាន់តែច្រើនចុះឈ្មោះចូលរៀន នោះសាលានឹងទទួលបានមូលនិធិសមធម៌សង្គមកាន់តែច្រើន។

**តួលេខទី១.លក្ខណៈវិនិច្ឆ័យស្នើសុំដើម្បីទទួលបានមូលនិធិសមធម៌សង្គម**

សាលាដែលមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោមនឹងមានសិទ្ធិទទួលបានមូលនិធិសមធម៌សង្គម ដើម្បីលើកកម្ពស់ជនក្រីក្រឲ្យទទួលបានការអប់រំមានស្តង់ដារអន្តរជាតិ។ សាលារៀនត្រូវមានលក្ខណៈវិនិច្ឆ័យចាំបាច់១០០%នៃលក្ខណៈវិនិច្ឆ័យជម្រើស៥០%។ ការបំពេញតាមលក្ខណៈវិនិច្ឆ័យដូចបានបញ្ជាក់ នឹងត្រូវបញ្ជាក់ដោយគណៈកម្មការត្រួតពិនិត្យការគ្រប់គ្រងសាលារៀនរបស់ក្រសួងអប់រំយុវជននិងកីឡាដែលបានបង្កើតឡើងនាពេលថ្មីៗនេះ ដឹកនាំដោយឯកឧត្តមណាត ប៊ុនរឿន ។

និយមន័យលក្ខខណៈវិនិច្ឆ័យសេវាកម្មនឹងផ្តល់ជូននៅផ្នែកបន្ទាប់នៃឯកសារនេះ។

| **លក្ខខណៈវិនិច្ឆ័យសេវាអប់រំ** | **ស្ថានភាពលក្ខណៈវិនិច្ឆ័យ** | | **កំណត់សម្គាល់** |
|---|---|---|---|
| | **ចាំបាច់** | **ជម្រើស** | |
| ១. លុបបំបាត់រៀនគួ (ពាក់ព័ន្ធការឡើងថ្នាក់ចុងឆ្នាំ) | √ | | |
| ២. លុបបំបាត់ការអនុវត្តទិញទំនិញរបស់គ្រូនៅក្នុងថ្នាក់រៀន (ឧ. នំ ក្រដាស់មេរៀន ។ល។) | √ | | |
| ៣. ម៉ោងសិក្សា ៦ម៉ោង/ថ្ងៃតាមស្តង់ដារអន្តរជាតិ | √ | | សម្រាប់បឋមសិក្សា |
| ៤. ភស្តុតាងបង្ហាញថាក្រុមប្រឹក្សាកុមារសកម្ម និងចូលរួមក្នុងការគ្រប់គ្រងសាលា | √ | | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដារ |
| ៥. ភស្តុតាងបង្ហាញថាគណៈកម្មការទ្រទ្រង់សាលាសកម្ម និងចូលរួមក្នុងការគ្រប់គ្រងសាលា។ | √ | | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដារ |
| ៦. ភស្តុតាងបង្ហាញថាមានការប្រជុំជាទៀតទាត់ជាមួយមាតាបិតាសិស្ស (តិចបំផុត២ដងក្នុងមួយឆ្នាំ)។ | √ | | |
| ៧. ភស្តុតាងបង្ហាញថាគ្រូប្រើវិធីសាស្ត្រសិស្សមជ្ឈមណ្ឌលយ៉ាងហោចណាស់ឲ្យបាន៥០%នៃថ្នាក់។ | | √ | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដារ |
| ៨. សម្ភារៈឧបទ្ទេសមានគ្រប់គ្រាន់ និងមានភស្តុតាងបង្ហាញថាមានការប្រើប្រាស់កម្រិតខ្ពស់ | √ | | |
| ៩. មានសៀវភៅពុម្ពគ្រប់គ្រាន់ (មួយច្បាប់សម្រាប់សិស្សម្នាក់គ្រប់មុខវិជ្ជាសំខាន់ៗទាំងអស់) | | √ | |
| ១០. ផលធៀបរវាងសិស្ស និងគ្រូត្រឹម ឬតិចជាងនេះ 40:1 | | √ | |
| ១១. ភស្តុតាងបង្ហាញថាមានការបង្រៀនបច្ចេកវិជ្ជាព័ត៌មាន (ឧ. អក្ខរកម្ម digital , ការរៀនដោយប្រើប្រាស់ tablets, ។ល។) | | √ | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដារ |
| ១២. ភស្តុតាងបង្ហាញពីកម្មវិធីបំនិនជីវិតដោយប្រើប្រាស់កម្មវិធីសិក្សាថ្មីដែលក្រសួងបានអនុម័ត | | √ | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដារ |
| ១៣. ភស្តុតាងបង្ហាញពីការផ្តល់សេវាប្រឹក្សាអាជីព | | √ | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដារ |
| ១៤. ភស្តុតាងបង្ហាញការផ្តល់សេវាប្រឹក្សាកុមារី | | √ | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដារ |
| ១៥. ភស្តុតាងបង្ហាញថាមានឧបករណ៍វាស់អំណានដែលបានអនុម័តឲ្យប្រើប្រាស់នាពេលថ្មីៗនេះសម្រាប់ថ្នាក់ទី១ និង២ | | √ | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដារ |
| ១៦. សកម្មភាពបន្ថែមលើកម្មវិធីសិក្សា(ឧ.ក្លិបមុខវិជ្ជា, កីឡា, សិល្បៈ។ល។) | | √ | |
| ១៧. មានស្តង់ដារខ្ពស់ ក្នុងការថែរក្សា និងអនាម័យអគារ | √ | | |
| ១៨. ស្តង់ដាខ្ពស់ចំពោះអនាម័យបង្គន់ | √ | | |
| ១៩. ភស្តុតាងបង្ហាញថាមានការគាំទ្រសិស្សក្រីក្រ (ឧ, គួរផែនទីសិក្សា, ផ្តល់អាហារូបករណ៍។ល។) | | √ | |
| ២០. បន្ទប់ពិសោធន៍វិទ្យាសាស្ត្រដែលមានអាត្រាប្រើប្រាស់ខ្ពស់ (សម្រាប់សិស្សមធ្យម | | √ | លក្ខណៈវិនិច្ឆ័យ |

| | | | |
|---|---|---|---|
| សិក្សាតែប៉ុណ្ណោះ) | | | តម្រូវតាមស្តង់ដារ |
| ២១. បណ្ណាល័ដែលមានអាត្រាប្រើប្រាស់ខ្ពស់ | √ | | លក្ខណៈវិនិច្ឆ័យ តម្រូវតាមស្តង់ដារ |
| ២២. មានសួនកុមារនិងទីធ្លាលេងកីឡា | | √ | |
| ២៣. មានថ្នាក់បំប៉នសិស្សរៀនយឺតដែលមានតម្រូវការជំនួយពិសេស | | √ | |
| ២៤. មានអាហារដ្ឋានសម្រាប់សិស្សដែលផ្តល់ជីវជាតិមានស្តង់ដារខ្ពស់ និងតំលៃសមរម្យ | | √ | |
| សរុប | **10** | **14** | |

## 5.2 តួនាទីរបស់ដៃគូអភិវឌ្ឍក្នុងការគាំទ្រមូលនិធិសមធម៌សង្គម

ដៃគូរអភិវឌ្ឍមានតួនាទីដ៏សំខាន់ក្នុងការធ្វើឲ្យមូលនិធិសមធម៌សង្គមដំណើរការទៅបាន ព្រោះថា សាលាជាច្រើនទំនងជាមិនអាចសម្រេចបាននូវគុណភាពអប់រំ និងរចនាសម្ព័ន្ធអភិបាលកិច្ចតាមតម្រូវការចង់បានដោយគ្មានការគាំទ្រពីខាងក្រៅនោះទេ។ ការគាំទ្របែបនោះកាន់តែមានសារៈសំខាន់ណាស់ជាពិសេសក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍសាលារៀនដែលទាមទារការវិនិយោគក្នុងការបណ្តុះបណ្តាល ឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធ។ ជាថ្មីម្តងទៀតតួនាទីម្ចាស់ជំនួយមួយចំនួនដូចជា USAID បានបំពេញក្នុងការជួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ក្នុងការកសាងសមត្ថភាពរហូតដល់កម្រិតមួយដែលពួកគេមានលក្ខណៈសម្បត្តិក្នុងការដាក់ពាក្យសុំវិញ្ញាបនប័ត្របញ្ជាក់ពី GPPនៅអង្គការ CCC ដែលអាចផ្តល់គំរូល្អសម្រាប់ម្ចាស់ជំនួយផ្សេងទៀតដើម្បីពិចារណា។ គំរូបែបនេះគឺមានប្រយោជន៍ក្នុងការធ្វើការកំណត់ការ វិនិយោគចាំបាច់ និងពីវិធីដែលការវិនិយោគទាំងនេះឈានទៅឲ្យទទួលបានវិញ្ញាបនប័ត្រ និងទទួលបានមូលនិធិសមធម៌សង្គម ។ គំនិតខ្លះៗស្តីពីការស្នើសុំគាំទ្រពីដៃគូអភិវឌ្ឍមានបង្ហាញនៅក្នុងប្រអប់ទី១។

ផ្លូវនៃការអភិវឌ្ឍយ៉ាងល្អមួយឧបត្ថម្ភធនធានដោយម្ចាស់ជំនួយក៏នឹងធានាឲ្យបាននូវនិរន្តរភាពនៃរាល់ ការវិនិយោគរបស់ម្ចាស់ជំនួយ ដោយសារតែការរក្សាបានវិញ្ញាបនប័ត្ររបស់សាលារៀនក៏នឹងធ្វើឲ្យសាលាបន្តទទួលបានមូលនិធិសមធម៌សង្គមពីរដ្ឋាភិបាល ទន្ទឹមនឹងវិភាគទានពីគ្រួសារមានជីវិភាពកម្រិតមធ្យមដែលជាភាគីឯកជននឹងបង្កើនប្រភពធនធានពីមូលដ្ឋានផ្ទាល់។ ទោះជាយ៉ាងនេះក្តី ប្រការសំខាន់គឺគណៈកម្មការត្រួតពិនិត្យថ្នាក់ជាតិក្នុងឋានៈជាស្ថាប័នចេញវិញ្ញាបនបត្រឲ្យសាលាត្រូវតែប្រកាន់ខ្ជាប់ខ្ជួននូវនូលក្ខណៈវិនិច្ឆ័យសិទ្ធិរបស់សាលារៀន និងមានឆន្ទៈធ្វើសេចក្តីសម្រេចដកហូតវិញ្ញាបនប័ត្រនៅពេលណាដែលចាំបាច់។ ជាថ្មីម្តងទៀតឆន្ទៈរបស់ CCC ក្នុងការដកយកវិញ្ញាបនប័ត្រពីអង្គការមិនមែន រដ្ឋាភិបាលដែលរកឃើញថាគ្មានលក្ខណៈសម្បត្តិពេញលេញនៅពេលវាយតម្លៃតាមជុំឡើងវិញបានផ្តល់គំរូល្អនៃភាពក្លាហាននេះ*ever*សម្រាប់ឲ្យរដ្ឋាភិបាលអនុវត្តតាម[7]។

[7] CCC renews NGO certification every 3 years and has in some cases withholds certification when NGOs no longer comply with eligibility criteria.